ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# ល្បែងប្រជាប្រិយខ្មែរ



ភ្នំពេញ

ព.ស. ២៥០៧ ស.គ. ១៩៦៤

www.elibraryofcambodia.org

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# ល្បែងប្រជាប្រិយខ្មែរ

តាមការស្រាវជ្រាវរបស់ក្រុមជំនុំទំនៀមទម្លាប់

ព្រមទាំង សមាជិកឆ្លើយឆ្លង គ្រប់ខេត្ត


រៀបរៀងដោយ :

លោក ចាក-ពិន អធិបតីក្រុមជំនុំ

អ្នកស្រី ពេជ្រ-សល់, លោក លី-ធាមតេង និង ស្ដីង-ឮ

សមាជិកនៃក្រុមជំនុំ

គំនូររបស់ លោក ចាប-ធូ



បោះពុម្ពលើកដំបូង

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥០៧ គ.ស. ១៩៦៤


www.elibraryofcambodia.org

Commission des Mœurs & Coutumes du Cambodge

# JEUX POPULAIRES
## AU
## CAMBODGE

d'après les travaux d'études et de recherches de la Commission des Mœurs et Coutumes

avec

le concours des membres correspondants

Rédigé

par :

M. CHAP PIN, Président de la Commission

Mme PICH SAL, MM. LY THEAM TENG & SDŒUNG CHHO

Membres de la Commission

Illustrations : M. CHAP NOU

Première édition

PHNOM-PENH

Editions de l'Institut Bouddhique

1964

www.elibraryofcambodia.org

# អារម្ភបទ

ប្រទេសកម្ពុជាមានល្បែងប្រជាប្រិយច្រើនជាអនេក ដែលប្រជាពលរដ្ឋទូទាំងប្រទេសនិយមលេងកំសាន្ត នៅពេលទំនេរ, ពេលបុណ្យទាន និងពេលធ្វើពិធីតូច-ធំផ្សេងៗ មានពិធីចូលឆ្នាំជាដើម ជាប់ជាប្រពៃណីតាំងពីព្រេងនាយមក ។

បើយើងសង្កេតដោយហ្មត់ចត់សព្វគ្រប់តាមលក្ខណការរបស់ល្បែងទាំងនោះទៅ ទើបឃើញថាមានប្រយោជន៍ខាងកាយសម្បទាខ្លះ ខាងចិត្តសម្បទាខ្លះ ដែលអាចកប់ចូលក្នុងអត្តពលកម្ម និងចិត្តពលកម្ម គឺជាការហាត់ប្រាណ ហាត់ក្អែក ហាត់ជើងដៃឲ្យរាងកាយកើតសាច់ឈាមមាំមួន មានសុខភាពល្អ មានកម្លាំងពលំ ក្អែកល៉ៃ ដៃជើងរហ័សរហួន ទើបជាការហាត់ចិត្តគំនិត ហាត់ប្រាជ្ញាស្មារតី ឲ្យមានគំនិតវាងវៃ ស្មារតីប៉ុងប៉ៅ ចេះគិតល្បិចផ្សេងៗ, មួយទៀតល្បែងទាំងនោះ ជាការ្យធម៌ចាស់របស់ខ្មែរសុទ្ធសាធ ដោយហេតុប្រទេសខ្មែរជាប្រទេសចាស់មួយ នៅអាស៊ីអាគ្នេយ៍ មានអាយុរាប់ពាន់ឆ្នាំមកហើយ ហេតុនេះហើយមានបង្កើតជាចំណេះចេះដឹង-ភ្លេង-ល្បែងជាច្រើន ។

ឯល្បែងទាំងនោះ ពុំមានចារឹកជាក្បួន ជាតម្រាទេ, គេលេងតែតាមចំណាំរបស់គេរៀងៗខ្លួន តៗគ្នាទៅតាមទម្លាប់ស្រុករបស់គេ ។

www.elibraryofcambodia.org

ការដែលពុំបានចារឹកល្បែងរបស់ខ្មែរទុកជាឯកសារនោះ នាំឲ្យល្បែងខ្មែរពុំអាចមានអាយុយឺនយូរតទៅបាន ហើយថែមទាំងឥទ្ធិពលនៃល្បែងបរទេសចេះតែចូលមកជ្រៀតជ្រែកគ្របសង្កត់ផងទៀត ល្បែងខ្មែរក៏រិតតែសាបរលាបបន្តិចម្តងៗ , តែការចារឹកជាក្បួនតម្រានោះមានការលំបាកក្រៃពេក លុះតែស្រាវជ្រាវរករកអស់ពេលយ៉ាងយូរទើបបានសម្រេច ។

ដើម្បីឲ្យការចារឹកនេះឆាប់បានសម្រេច លោក ចាប ពិន អធិបតីក្រុមជំនុំ រួបរួមជាមួយសមាជិកនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ក៏ស្រាវជ្រាវជ្រើសយកល្បែងផ្សេងៗ អំពីឯកសាររបស់សមាជិកឆ្លើយឆ្លងនៅក្នុងក្រុងនិងខែត្រក្រៅទាំងឡាយ ដែលមានក្នុងក្រុមជំនុំទំនៀមទម្លាប់ខ្លះ ស៊ើបសួរយកការណ៍អំពីលោកអ្នកចាស់ទុំ ដែលចេះចាំនូវល្បែងនោះៗខ្លះ រៀបចំចងក្រងជាសៀវភៅនេះ ឲ្យឈ្មោះថា "ល្បែងប្រជាប្រិយខ្មែរ" ហើយដាក់ឲ្យគណៈកម្មការពិសេសមួយដែលតាំងឡើងដោយកំណត់ក្រសួងលេខ ៥៥/O.S ចុះថ្ងៃ ១៣ ខែមីនា គ.ស. ១៩៦៤ នៃក្រសួងធម្មការពិនិត្យថែម រួបចាត់ការបោះពុម្ពឡើង ដើម្បីរក្សាទុកនូវល្បែងជាប្រពៃណីរបស់ជាតិ ឲ្យមានអាយុយឺនយូរបំផុតថេរកាលជាអង្វែងតទៅ សម្រាប់ឲ្យយុវជនរួមជាតិសម័យបច្ចុប្បន្ន និងអនាគតជ្រាបច្បាស់ថា ល្បែងប្រពៃណីជាតិរបស់ខ្លួនមានប្រយោជន៍យ៉ាងណាខ្លះ ។

www.elibraryofcambodia.org

នៅវេលាបោះពុម្ពសៀវភៅនេះ លើកទី ១ យើងយល់ថាពុំទាន់បានសព្វគ្រប់ល្បែងនៅឡើយទេ ។ ដូច្នេះ ក្រុមជំនុំសូមអំពាវនាវដល់លោកអ្នកទាំងឡាយ បើឃើញថា នៅខ្វះល្បែងអ្វីខ្លះ សូមសរសេរតែងល្បែងនោះដោយសព្វគ្រប់ល្មមធ្វើជាគម្រូលេងតាមបាន ទៅឲ្យក្រុមជំនុំទំនៀមទម្លាប់ នៅពុទ្ធសាសនបណ្ឌិត្យ, ក្រុមជំនុំនេះនឹងរៀបរៀងបញ្ចូលថែមឲ្យបានសព្វគ្រប់នៅវេលាបោះពុម្ពលើកទី ២ តទៅ ។

ភ្នំពេញ ថ្ងៃទី ១៥ មេសា ១៩៦៤

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

www.elibraryofcambodia.org

# សេចក្តីកត់ហេតុ

គណៈកម្មការមួយតែងតាំងឡើងដោយកំណត់ក្រសួងលេខ១៥៥/ ០.ន ចុះថ្ងៃទី ១៣ ខែមីនា គ.ស. ១៩៦៤ នៃក្រសួងធម្មការ ដែលមាន សមាសភាពដូចតទៅ ៖

១- សហជីវិន ចាប - ពិន នៅពុទ្ធសាសនបណ្ឌិត្យ ប្រធាន

២- — អ៊ុម - ជុំ សមាជិករដ្ឋសភា សមាជិក

៣- ឧកញ៉ារាជវរានុកូល គីម - យឹង នៅព្រះបរមរាជវាំង —

៤- ឧកញ៉ាប្រសើរលេខា កោត - រឿង សាលាវិចិត្រសិល្បខេមរៈ សមាជិក

៥- សហជីវិន ញួង - សៀង នៅពុទ្ធសាសនបណ្ឌិត្យ សមាជិក

៦- សហជីវិនី ពេជ្រ - សល់ -ដ- -ដ-

៧- សហជីវិន លី - ធាមតេង -ដ- -ដ-

៨- — ស្តើង - ឈួរ -ដ- លេខាធិការ

បានប្រជុំគ្នាអស់ ១១ លើក ដើម្បីពិនិត្យសៀវភៅ ល្បែងប្រជាប្រិយខ្មែរ នេះ ដែលក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បានតែងហើយ ដាក់ស្នើមកឲ្យគណៈកម្មការនេះពិនិត្យ ។

www.elibraryofcambodia.org

គណៈកម្មការយល់ឃើញថា ទោះបីពុំទាន់បានសព្វគ្រប់ទាំងអស់ដោយសារជាលើកដំបូងក្តី, ក៏សៀវភៅនេះ ហុចផលប្រយោជន៍ជាច្រើនដល់អ្នកអានទូទៅ ក្នុងការស្គាល់ច្បាស់នៃល្បែងប្រជាប្រិយ ដែលជាវប្បធម៌ផ្ទាល់របស់ជាតិខ្មែរ ។

ក្រោយដែលបានពិនិត្យផ្ទៀងផ្ទាត់សព្វគ្រប់ទៅ គណៈកម្មការបានកែសម្រួលខ្លះ បន្ថែមសេចក្តីខ្លះ ឲ្យកាន់តែបានសមរម្យឡើង ល្មមសមគួរឲ្យយកទៅបោះពុម្ពផ្សាយទុកជាទិដ្ឋានុគតិតទៅ ។

ភ្នំពេញ ថ្ងៃទី ៣ វិច្ឆិកា គ.ស. ១៩៦៤

ប្រធានគណៈកម្មការ,

ហត្ថលេខា : ចាប-ពិន

សមាជិក,

ហត្ថលេខា : — អ៊ុម-ជុំ

— គឹម-យ៉ឹង

— កោត-រឿន

— ញុង-សៀង

— ពេជ្រ-សល់

— លី-ធាមតេង

— ស្តើង-ធូរ

www.elibraryofcambodia.org

# បញ្ជីរឿង


| រឿង | | | ទំព័រ |
|---|---|---|---|
| | អារម្ភបទ. | | |
| ១– | ល្បែង | ស្តេចចង់ ឬ អៀវ | ១ |
| ២– | – | ឈូង | ៥ |
| ៣– | – | ចាប់កូនខ្លែង | ១០ |
| ៤– | – | លោតអន្ទាក់ | ១៤ |
| ៥– | – | លាក់កន្សែង | ១៨ |
| ៦– | – | ទបគ្រឡាប | ២១ |
| ៧– | – | ប្រជល់មាន់ | ២៤ |
| ៨– | – | គ្របមាន់ | ២៦ |
| ៩– | – | បិទពួន | ២៩ |
| ១០– | – | អង្គុញ | ៣៣ |
| ១១– | – | គោះពញ្ញាក់ | ៤៤ |
| ១២– | – | គោះគ្រឡោក | ៤៧ |
| ១៣– | – | សី | ៥០ |
| ១៤– | – | ទាញព្រ័ត្រ | ៥៦ |


www.elibraryofcambodia.org

| រឿង | | | ទំព័រ |
|---|---|---|---|
| ១៥– | ល្បែង | កូនគោល | ៦០ |
| ១៦– | – | ពាំបង្កង | ៦៤ |
| ១៧– | – | ចោះប្រមាត់ | ៦៦ |
| ១៨– | – | ចាយខុំ | ៦៩ |
| ១៩– | – | លាក់កូនកាស | ៧៣ |
| ២០– | – | លាក់កន្សែង | ៧៦ |
| ២១– | – | ប៉ក់ចាប | ៧៩ |
| ២២– | – | ចក្រង្គ | ៨៤ |


www.elibraryofcambodia.org

# ល្បែងប្រជាប្រិយខ្មែរ

www.elibraryofcambodia.org

# ១– ល្បែងស្តេចចង់ ឬ ល្បែងអៀវ

**ល្បែងស្តេចចង់** ជាល្បែងមួយយ៉ាងដែលពួកកុមារកុមារីជំទង់ៗ គ្រប់ភូមិ-ស្រុក ទូទាំងកម្ពុជរដ្ឋ តែងលេងនៅពេលទំនេរក្នុងវេលាយប់ខែភ្លឺ ។ អ្នកលេងមានប្រុសមានស្រីច្រើននាក់ មិនកំណត់ ។ ពេលលេងគេចែកគ្នាជា ២ពួក ប្រុស ១ពួក ស្រី ១ពួក ។ ក្នុងបណ្តាអ្នកទាំង ២ពួកនោះ គេតាំងប្រុស ឬស្រីម្នាក់ឲ្យធ្វើជាស្តេច ឲ្យអង្គុយនៅទីមួយចំកណ្តាលទី លើកៅអីឬលើត្រូមួយ មានត្បាល់ជាដើម ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



www.elibraryofcambodia.org

កាលអ្នកធ្វើស្តេចអង្គុយលើទីដ៏សមគួរមួយហើយ, ខាងស្រីគេឲ្យស្រីម្នាក់ដើរចូលទៅខ្សឹបទឹងស្តេចថា ខ្ញុំស្រឡាញ់ឈ្មោះណាមួយ ឧបមាថា ឈ្មោះ ក ឬ ខ ខ្សឹបហើយគេថយមកអង្គុយ ឬក៏មកឈរនៅកន្លែងដើមវិញៗ ខាងប្រុសគេឲ្យប្រុសម្នាក់ដើរចូលទៅរកស្តេចដែរ ប្រសិនជាមិនចំឈ្មោះដែលគេខ្សឹបទុកជាមុនទេក៏ហើទៅ តែបើប្រុសដែលមកនោះចំលើឈ្មោះដែលស្រីគេបានខ្សឹបនោះមែន ស្តេចស្រែកថា “អៀវៗ” ហើយឲ្យស្រីនោះជិះប្រុសនោះតម្រង់ទៅរកកន្លែងគេ, កំពុងជិះ គេស្រែកថា “អៀវៗ” ហើយគេបញ្ជិះទៅចុះនៅកន្លែងខាងស្រី ៗ រួចហើយខាងប្រុសគេឲ្យប្រុសខាងគេម្នាក់ចូលទៅខ្សឹបម្តង, បើប្រុសនោះចូលទៅខ្សឹបថា “ខ្ញុំស្រឡាញ់នាងណាមួយ ឧបមាថាឈ្មោះ “ខ” ខ្សឹបហើយគេថយទៅវិញ បើស្រីម្នាក់ឈ្មោះ “ខ” ចូលទៅមែន ស្តេចស្រែកថា „អៀវៗ” ហើយឲ្យប្រុសនោះជិះស្រីនោះ ស្រែកថា “អៀវៗ” ដូចគ្នា ៗ បានសេចក្តីថា បើខាងណាចូលទៅខ្សឹបថា ខ្ញុំស្រឡាញ់ឈ្មោះ “ក” ហើយបែរជា ឈ្មោះ “ខ” ចូលមករកស្តេចវិញ នោះស្តេចមិនឲ្យអ្នកខ្សឹបជិះ

www.elibraryofcambodia.org

ឬអៀវគេទេ អ្នកខ្សែបនោះត្រូវថយទៅវិញ ហើយគេឲ្យម្នាក់ចូលទៅខ្សែប ជាថ្មីទៀត ។ បេះតែផ្លាស់គ្នាតាមរបៀបនេះរហូតដល់ពេលឈប់ ។

អ្នកដែលធ្វើស្តេចត្រូវមើលការខុសត្រូវក្នុងរឿងនេះ ដោយសច្ចៈ និងយុត្តិធម៌ ។

ល្បែងនេះស្រេចលើអ្នកធ្វើស្តេច បើអ្នកធ្វើស្តេចប្រកបដោយ អគតិ ចង់ឲ្យអ្នកណាជិះអ្នកណា ក្រៅពីឈ្មោះដែលគេខ្សែបក៏បាន គឺថា បើម្នាក់ចូលទៅខ្សែបថាស្រឡាញ់ឈ្មោះ " ក " ហើយទោះបីឈ្មោះ " ខ " ចូលមក ស្តេចស្រែកថា " អៀវ " ទៅក៏បេះតែបាន ព្រោះអ្នកចូល ទៅក្រោយ មិនបានឮអ្នកមុនគេខ្សែបថា ស្រឡាញ់ឈ្មោះណា ៗ ទេ ។ តែបើមានរបៀបលេងលំអៀងបែបនេះ អ្នកលេងណាដែលចាប់ថ្នាក់បាន តក់ឡើង អាចសុំគេឲ្យប្តូរអ្នកធ្វើស្តេចបាន ប្រសិនបើអ្នកធ្វើស្តេចប្រកប ដោយសច្ចៈនិងយុត្តិធម៌ នោះការលេងនេះនឹងទៀងទាត់ណាស់ ។

ល្បែងនេះជាល្បែងកំសាន្តក៏មែន តែជាល្បែងហាត់ចិត្តមនុស្សឲ្យ ប្រកបដោយសច្ចៈនិងយុត្តិធម៌ មិនឲ្យប្រកបដោយអគតិ (សេចក្តីលំអៀង) ៤ យ៉ាងគឺ ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់, ទោសាគតិ លំអៀង

www.elibraryofcambodia.org

ព្រោះខឹង, ភយាគតិ លំអៀងព្រោះខ្លាច, មោហាគតិ លំអៀងព្រោះភ័ន្តច្រឡំ ។ មួយយ៉ាងទៀត ជាការបង្ហាត់ឲ្យមនុស្សចេះជ្រើសតាំងគ្នាឲ្យធ្វើការជាតំណាងក្នុងក្រុមខ្លួនផង គឺត្រូវចេះជ្រើសរកតែអ្នកណាដែលគេយល់ថាជាមនុស្សត្រឹមត្រូវបរិសុទ្ធ ធ្វើការបានល្អតាមគន្លងធម៌ពិត ៗ ។

※

※ ※

# ២_ ល្បែងឈូង

ល្បែងឈូង ជាល្បែងមួយយ៉ាង របស់មនុស្សកម្លោះក្រមុំ ឬ មនុស្សចំណាស់ៗប្រុស-ស្រី ទូទាំងកម្ពុជរដ្ឋ គេតែងលេងនៅវេលាយប់ ខែក្ដី ក្នុងរដូវចូលឆ្នាំថ្មី ( ខែចេត្រ-ពិសាខ ) ។ គេចែកគ្នាជា ២ ពួក ប្រុស ១ ពួក, ស្រី ១ ពួក ។ ក្នុង ១ ពួកៗ, មានគ្នាចំនួនពី ១០ នាក់ ឬ ២០ នាក់ ឡើងទៅ ឈរត្រៀមជា ២ ជួរ, ទល់មុខគ្នា ឃ្លាតពីគ្នា ប្រមាណជា ៨ ឬ ១០ ម៉ែត្រ ។ គេយកក្រមាឬកន្សែងមកធ្វើឲ្យមូល បង់រឹតឲ្យតឹងណែនល្អ ទុកឲ្យមានកន្ទុយបន្តិចហៅថា «ឈូង» សម្រាប់កាន់បោះឬចោលទៅមកគ្នា ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



www.elibraryofcambodia.org

## ឈូងមាន ២ បែប ៖

### ១–ឈូងប្រៀងរាំ

### ២–ឈូងលោះខ្ញុំ

១– ឈូងប្រៀងរាំ មុនដំបូង ពួកខាងប្រុសបោះឈូងទៅឲ្យពួកខាងស្រី, ពួកខាងស្រីប្រុងចាប់កុំឲ្យធ្លាក់ដល់ដី បើធ្លាក់ដល់ដី គេចាត់ជាស្អុយ ហើយគេផ្ដើមបោះទៅឲ្យខាងប្រុសវិញ, ពួកខាងប្រុសប្រុងចាប់កុំឲ្យធ្លាក់ដល់ដី ។ កាលចាប់បានហើយ ពេលសំដៅទៅពួកខាងស្រី គឺសំដៅនាងណាដែលខ្លួនស្ម័គ្រ បើពេលខុសគេចាត់ជាស្អុយ រួចគេផ្ដើមបោះជាថ្មីទៀត បើពេលត្រូវស្រីណាហើយ ស្រីនោះប្រៀងនាំយកឈូងទៅជូនខាងប្រុស ហៅថាប្រៀងនាំជូនឈូង ។ របៀបប្រៀងនាំនោះ ម្នាក់កាន់ឈូងនាំមុខ ម្នាក់ដៃទទេនាំតាមក្រោយ ហើយប្រៀងជាចំនុកថា “ ប្អូនចាប់ឈូងបាន ឈូងបែកជាបួន ព្រលឹងប្រុសស្ងួន ទទួលឈូងទៅ ” ។ ពួកស្រីៗក្រៅពីនោះគ្រប់គ្នាទទួលថា “ ឱណាកែវ កែវពិសា ឱណាកែវអើយ អឺអឹងអើយ ! ” រួចហើយហុចឈូងនោះទៅឲ្យប្រុសៗ ទទួលយក ហើយក៏ផ្ដើមបោះ

www.elibraryofcambodia.org

ឈូងនោះទៅឲ្យពួកខាងស្រីចាប់វិញ ។

បើពួកស្រីចាប់ឈូងបានក៏គោលសំដៅទៅពួកប្រុស បើគោលត្រូវប្រុសណា ប្រុសនោះត្រូវពាំនាំឈូងទៅជូនស្រី ដោយច្រៀងជាចំនុកថា "បងចាប់ឈូងបាន បងបីត្រកង ព្រលឹងមាសបង ទទួលឈូងទៅ" ។ ពួកប្រុស ។ គ្រប់គ្នាទទួលបន្ទរថា "ឱណាកែវ កែវពីអា ឱណាកែវអើយ អឺអឹងអឺយ !" ហើយក៏ហុចឈូងនោះទៅឲ្យពួកស្រី ។ ទទួលយក ទើបផ្ដើមបោះតទៅទៀត ។

២— ឈូងលោះខ្ញុំ ដើមដំបូង ខាងប្រុសគេផ្ដើមច្រៀង ១ ចំនុកជាមុន ។ ឯចំនុកច្រៀងឈូងមានច្រើនបែប ប្លែក ។ ទៅតាមប្រាជ្ញារបស់អ្នកនាំច្រៀងនិងតាមស្រុក ។ ទីនេះស្រង់យកតែចំនុកជម្មតា ដែលអ្នកលេងឈូងគ្រប់ស្រុកតែងច្រៀងគ្រប់គ្នាថា ៖ "បងបោះឈូងទៅ អូនអើយ កំពស់បុងរ្លង (ស្ទួន) ក្រមុំឈរប្រុង អូនអើយទទួលឈូងបង" ឬថា "បងបោះឈូងទៅ ឈូងបែកជាប្អួន ស្រីណាមានខ្លួន ទទួលឈូងបង" ។ល។ ច្រៀងហើយគេស្រែកប្រាប់ថា "ឈូងអើយ

www.elibraryofcambodia.org

ឈូង!„ ហើយអ្នកផ្ដើមទំនុកក៏បោះឈូងទៅលើពួកស្រី ៗ ឲ្យពួកស្រី ៗ ចាប់ ៗ ខាងស្រីចាប់ឈូងបាន គេបោលសំដៅទៅរកប្រុសណាដែលត្រូវចិត្ត បើបោលទៅត្រូវប្រុសណា គេទៅចាប់យកប្រុសនោះមកទុកខាងពួកគេ ៗ បើបោលមិនត្រូវទេ ខាងប្រុសគេចាប់ឈូងនោះបោលសំដៅមករកស្រីណាដែលគេស្ម័គ្រ បើខាងប្រុសបោលមកត្រូវខាងស្រីហើយ ប្រុសម្នាក់ដែលស្រីចាប់យកទៅលើកមុននោះ ត្រូវបានរួចខ្លួន បើប្រុសបោលមិនត្រូវស្រីវិញទេ ប្រុសម្នាក់នោះត្រូវនៅខាងស្រីដដែល ៗ បើខាងណាប៉ិនប្រសប់គេបោលយកខាងម្ខាងទាល់តែអស់ ៗ កាលណាអស់គ្នាហើយគេផ្ដើមលេងសាជាថ្មី ដោយឲ្យខាងស្រីបោះឈូងទៅឲ្យខាងប្រុសមុនវិញ ៗ មុននឹងស្រី ៗ បោះឈូងទៅឲ្យប្រុស គេស្រែកច្រៀងថា " អូនបោះឈូងទៅ បងអើយ កំពស់ចុងស្លា ប្រុសឈរត្រៀបត្រា បងអើយទទួលឈូងប្អូន " ។ល។ ច្រៀងហើយគេស្រែកថា " ឈូងអើយ ឈូង! " ហើយគេបោះឈូងទៅលើពួកប្រុស ៗ ។

ឯខាងប្រុស បើគេចាប់ឈូងខាងស្រីបានហើយ គេបោលឈូងនោះសំដៅទៅស្រី ៗ កាលត្រូវលើស្រីណាម្នាក់ គេចាប់យកស្រីនោះមកទុក

www.elibraryofcambodia.org

ខាងគេ ៗ បើខាងណាអស់មនុស្ស គេចែកគ្នាលេងសាជាថ្មី ៗ

មនុស្សដែលគេចាប់បាននោះ ជួនកាលគេចងមុខឲ្យជិត លែងឲ្យរត់ទៅកាន់ទីផ្សេង ៗ ជាការកំសាន្តសប្បាយ ៗ

របៀបលេងបែបទី ២ នេះ ជួនកាលអ្នកលេង គេប្រូតកាត់មិនចាប់ច្រៀង ស្រាប់តែហៅលែងម្តងក៏មាន ៗ

ល្បែងនេះ រាប់ចូលក្នុងពួកការហាត់ក្អែកឲ្យរៃ ហាត់ដៃឲ្យត្រង់ផង ជាការកំសាន្តសប្បាយ ដោយមានការរាំច្រៀងលាយជាមួយផង ៗ

www.elibraryofcambodia.org

# ៣- ល្បែងចាប់កូនខ្លែង

ល្បែងចាប់កូនខ្លែង ជាល្បែងរបស់កុមារកុមារីដ៏ទន់ ៗ តែងលេងក្នុងវេលាយប់ខែភ្លឺ នៅរដូវចូលឆ្នាំ ឬនៅពេលទំនេរ ៗ

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



ល្បែងនេះ ពេលលេងគេចាត់ម្នាក់ដែលមានមាឌមាំធំ ឲ្យធ្វើជាមេហ្វូងហៅថាមេមាន់, ចាត់ច្រើននាក់ឲ្យធ្វើជាកូនមាន់ ហើយគេចាត់ម្នាក់ទៀត ឲ្យធ្វើជាខ្លែង ចាំចាប់កូនមាន់ ៗ ម្នាក់ ៗ គេយកក្រមាក្រវាត់ចង្កេះឲ្យតឹងណែន ការពារកុំឲ្យរបូតសំលៀក ៗ គេនាំគ្នាបង្កាត់ភ្លើងឲ្យបានជា

www.elibraryofcambodia.org

ភ្នក់១តូច ដោយកំទេចឧស ហើយម្នាក់ដែលធ្វើមេមាន់បញ្ជាឲ្យកូនរបស់ខ្លួនតោងចង្កេះតៗគ្នា រហូតដល់អស់ ដោយឈរជាជួរ រួចដើរក្រឡឹងព័ទ្ធជុំភ្នក់ភ្លើង ៗ ជាមួយគ្នានេះ មេមាន់ពោលពាក្យបំអកឡកឡឺយ ឲ្យទៅខ្លែងថា ៖

ចាប់កូនខ្លែងប្រទៀងកូនអក
ពពោចញៀកញៀក កូនអញតែមួយ ៗ
ដឹកអន្លង់ដាំត្រកួន
ទន្សាយរត់ពួន ត្រកួនឡើងលាស់ ។
ទៀន ១ គូ តាំងយូបាំងព្រះ
លើកដៃសំពះ ដួន ៗ សុំភ្លើង ៗ

ចំណែកម្នាក់ដែលធ្វើខ្លែងឈរធ្វើព្រងើយ, កាលបានឮមាន់និងកូនមាន់ស្រែកដូច្នោះ ក៏ដើររួលទៅរកភ្នក់ភ្លើង ហើយនិយាយសុំភ្លើងថា "ដួន ៗ សុំភ្លើង !" ។

មាន់ឆ្លើយថា : រលត់

ខ្លែងសុំថា : សុំមួយអង្កត់

www.elibraryofcambodia.org

ខ្លែង កាលបានឮមេមាន់ថា ឲ្យកូនណាក៏បាក់កំបែកដូច្នេះ ក៏តាំងដេញចាប់បេះយកកូនណាដែលនៅក្រោយគេ, ឯមេមាន់ចាំប្រឹងការពារកូនរបស់ខ្លួនកុំឲ្យគេបេះយកបាន, ឯកូនមាន់ ក៏ចាំប្រឹងតោងចង្កេះគ្នា យ៉ាងជាប់ រត់ពេនចុះពេនឡើង ខ្លាចខ្លែងចាប់បេះយកខ្លួនម្នាក់ៗ បាន ។ ជួនក៏ខ្លែងបេះយកកូនបានម្តង ១ ម្តង ២ ទាល់តែអស់ ជួនក៏បេះបានតែ ១ ។ តែគេមានលក្ខខណ្ឌមួយថា បើកូនណារបូតចេញពីមេព្រោះប្រឹងគេចខ្លាំង ហើយកូននោះគេក្រាបទៅនឹងដី នោះមេខ្លែងមិនត្រូវចាប់គេទេ ។ កាលអស់កម្លាំងហត់រៀងខ្លួនហើយ ក៏ឈប់សម្រាកបន្តិច ហើយផ្លាស់ប្តូរគ្នាលេងតទៅទៀត គេលេងតែរបៀបនេះរហូតដល់ពេលឈប់ ។

ប៉ុន្តែល្បែងបែបដូចគ្នានេះ នៅស្រុកខ្លះ គេហៅត្រូវន័យតាមរបៀបលេងថា "ល្បែងខ្លែងចាប់កូនមាន់" ក៏មាន ។

ល្បែងនេះ ជាការបង្ហាត់មនុស្សឲ្យចេះប្រុងស្មៀត ប្រុងស្មារតីឲ្យរហ័សរហួន ចេះការពារខ្លួននិងគ្រួសារផង ។

※

※ ※

www.elibraryofcambodia.org

# ៤ ល្បែងលោតអន្ទាក់

ល្បែងលោតអន្ទាក់ ជាល្បែងសម្រាប់កុមារកុមារីដទៃៗ លេងក្នុងវេលាយប់ នៅរដូវចូលឆ្នាំ ឬនៅពេលទំនេរខ្លះ តាមដែលគេស្ម័គ្រ ៗ បានជាគេហៅថា “ល្បែងលោតអន្ទាក់” ព្រោះល្បែងនេះមានមនុស្សមួយពួកអង្គុយប្រហាន់ដំកង់ ចាប់ចុងដៃគ្នាជាអន្ទាក់ដៃ ចាំស្ទាក់អ្នកលោតកុំឲ្យលោតចូលបាន, មួយពួកទៀត ឈរជុំវិញចាំលោតរំលងឲ្យចូលទៅក្នុងអន្ទាក់ដៃនោះ ៗ របៀបលេងល្បែងនេះ គេចែកពួកអ្នកលេងជា២ ចំនួនស្មើគ្នា គឺចាប់តាំងពី ៤ ឬ ៦ នាក់ម្នាក់ឡើងទៅ ៗ

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



www.elibraryofcambodia.org

ពួកទី ១ អង្គុយប្រហោងដប់គ្នាជារង្វង់ ឃ្លាតពីគ្នាល្មមលោត ឬកាន់ដៃទាំងពីរខាងបាន ហើយចាប់ចុងដៃគ្នានិងគ្នា មើលទៅឃើញភាពដូចជាអន្ទាក់ ។

ពួកទី ២ ឈរជុំវិញ ចាំលបន្ទុក់ លោតចូលក្នុងអន្ទាក់ដៃរបស់ពួកទី ១ ។

ពេលលេង ពួកទាំង ២ នេះ សុទ្ធតែប្រុងប្រយ័ត្នរៀងខ្លួន គឺមុននឹងលោតចូល ពួកអ្នកឈរគេធ្វើរេរ៉ា ជុំវិញពួកអ្នកអង្គុយ ឲ្យពួកអ្នកអង្គុយភ្លេចខ្លួន ឬពួកអ្នកលោតគេបាត់ឲ្យពួកគេខ្វះទៅពួនទៅទីឆ្ងាយ ហើយឲ្យល្បួចតែពីចម្ងាយមកលោតចូលតែម្តងក៏មាន ។ ចំណែកខាងពួកអ្នកអង្គុយធ្វើអន្ទាក់ក៏ប្រុងប្រយ័ត្នដែរ ដើម្បីកុំឲ្យពួកអ្នកលោត លោតផ្លោះចូលមកក្នុងរង្វង់បាន ។ ឯពួកអ្នកអង្គុយគេលើកដៃឡើង ដោយប្រញាប់ជាបន្ទាន់ ដើម្បីកុំឲ្យគេលោតចូលបាន ឬដើម្បីលើកដៃគះឲ្យប៉ះជើងអ្នកលោត ។ បើអ្នកអង្គុយគះប៉ះជើងអ្នកលោតបានហើយ គេទុកអ្នកលោតជាចាញ់ អ្នកធ្វើអន្ទាក់ជាឈ្នះ ហើយអ្នកឈ្នះក្រោកឈរឡើងចាំលោត ឲ្យអ្នកចាញ់ទៅអង្គុយធ្វើអន្ទាក់វិញ ។ ឯពួកអ្នកលោតនោះ បើមានអ្នកណាម្នាក់លោតចូលបានដោយស្រួល គេឲ្យគ្នាគេទាំងអស់ចូលតាមទៅក្នុងរង្វង់អន្ទាក់នោះ ហើយពួកអ្នកលោតចូលបាននោះ គេនាំគ្នាលោតចេញវិញ គឺអ្នក

www.elibraryofcambodia.org

ះលោតចូលបាននោះ គេឈរគ្រប់គ្នាតាមជើងលើអន្ទាក់ដៃអ្នកអង្គុយគ្រប់នា ទុកជើងម្ខាងនៅក្នុងជើងម្ខាងនៅក្រៅអន្ទាក់ដៃនោះ ៗ បើក្នុងបណ្ដាពួកអ្នកលោតនោះ មានអ្នកណាម្នាក់ លោតចេញដោយស្រួលបានមិនប៉ះដៃអ្នកអង្គុយ គេនាំគ្នាចេញតាមទាំងអស់ ៗ តែការចេញនិងចូលបាននោះត្រូវចេញ ឬចូលឲ្យចំច្រកដែលលោតរំលងបាននោះ បើខុសច្រកនោះទេទុកជាចាញ់ ៗ ហើយការលោតចូល ឬលោតចេញនោះត្រូវតែលោតម្ដងម្នាក់ បើជួនជាស្រួបពីរនាក់ស្មើគ្នា ក៏គេទុកជាចាញ់ដែរ ៗ គេចេះតែផ្លាស់ប្ដូរគ្នាលេងតាមរបៀបនេះរៀងទៅដរាបដល់ពេលឈប់ ៗ

ល្បែងនេះ ជាល្បែងកសាន្តមួយយ៉ាង ដែលចាត់ចូលក្នុងកីឡាហាត់ប្រាណ គឺហាត់កាយឲ្យមានសុខភាព មានកម្លាំងកាយរឹងប៉ឹងកាត់ក្អែកឲ្យវៃ ហាត់ស្មារតីឲ្យចេះប្រុងប្រយ័ត្ន ចេះប្រើគំនិតឲ្យវាងវៃរៀអ្នកដទៃបំភ័ន្តបាន

※

※ ※

www.elibraryofcambodia.org

# ៥- ល្បែងលាក់កន្សែង

ល្បែងលាក់កន្សែង ជាល្បែងមួយយ៉ាងរបស់ក្មេងខ្មែរក្នុងបុរាណកាលតែងលេងសម្រាប់ជាទីកំសាន្តសប្បាយ នៅពេលយប់ខែភ្លឺក្នុងរដូវបុណ្យចូលឆ្នាំ ឬនៅពេលជាចន្លោះការហាត់រៀនម្តង ៗ ។

មុនដំបូង ពួកក្មេងៗគេប្រមូលគ្នាបានចំនួនពី ៦-៧ នាក់ឡើងទៅឡើងអង្គុយប្រហែរជុំកងជារង្វង់មូល ដាក់ដៃទាំងពីរទៅមុខលើក្បាលជង្គង់ក្នុងទីណាមួយដែលជាទីវាលស្រឡះរាបស្មើល្អ ។ ហើយគេយកកន្សែងឬក្រមាតូចមួយមករមូរមួលរឹតឡើងតឹងណែនល្អ ទុកជួយបន្ទុចសម្រាប់ការយួរបាន សន្មតហៅថា កន្សែង មានម្នាក់ក្រោកចេញទៅក្រៅរង្វង់កាន់កន្សែងនោះ ដើរព័ទ្ធជុំវិញយ៉ាងលឿន ពីខាងក្រោយខ្នងអ្នកអង្គុយបញ្ឆោតអ្នកអង្គុយមិនឲ្យដឹងខ្លួនថា គេលាក់កន្សែងក្រោយខ្នងអ្នកណា ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពខាងមុខនេះ ៖

www.elibraryofcambodia.org



ល្បែងនេះ មានគេហាមយ៉ាងតឹងរ៉ឹងមិនឲ្យអ្នកលេងដាក់ក្រោយ ឬលូកដៃទៅខាងក្រោយខ្លួន បើអ្នកណាមួយហ៊ានដាក់ ឬលូកស្ទាបខាងក្រោយខ្លួន អ្នកលាក់គេមានអំណាចដាក់ទណ្ឌកម្មអ្នកនោះ មិនឲ្យឡើងលាក់កន្សែង ឬគេឲ្យអ្នកនោះអង្គុយធ្វើជាកូនក៏បាន ស្រេចតែគេដាក់ទោសយ៉ាងណាតាមចិត្តគេស្រេច ។ អ្នកលាក់ លុះរត់ក្រឡឹងអ្នកអង្គុយ ២-៣ជុំហើយ មើលតែអ្នកណាអង្គុយបែបភ្លេចខ្លួនគេក៏ដាក់កន្សែងក្រោយខ្នងអ្នកនោះភ្លាម រួចគេរត់យ៉ាងហ័សព័ទ្ធវង់អ្នកអង្គុយ ដើម្បីឲ្យឆាប់មកដល់កន្លែងកន្សែងដែលគេដាក់នោះ ។ បើអ្នកដែលត្រូវគេលាក់កន្សែងពីក្រោយខ្នងនោះមិនដឹងខ្លួន លុះអ្នកលាក់គេរត់ក្រឡឹងមកម្តងទៀតចាប់យកកន្សែងនោះបានមុន គេទុកអ្នកលាក់នោះជាឈ្នះ ត្រូវមានអំណាចរើសយកកន្សែងទៅគក់ខ្នងអ្នកដែលអង្គុយនោះ ហើយគេយកកន្សែងលាក់តទៅទៀត ។ តែបើអ្នកអង្គុយដឹងខ្លួនថា គេលាក់កន្សែងចំក្រោយខ្នងខ្លួន

www.elibraryofcambodia.org

ហើយចាប់យកកន្សែងបានមុនអ្នកលាក់តែមកដល់ គេចុកអ្នកអង្គុយនោះ ជាឈ្នះ ត្រូវមានអំណាចក្រោកឡើងចាប់កន្សែងដេញគក់អ្នកលាក់នោះវិញ តែបើអ្នកនោះគេរត់ទៅដល់កន្លែងចន្លោះអង្គុយបានទៅ អ្នកកាន់កន្សែងនោះ មិនត្រូវគក់គេទេ ត្រូវតែក្រឡឹងអ្នកអង្គុយដំកង់ ដើម្បីនឹងលាក់តទៅទៀត គឺថា អ្នកលាក់ពីមុនត្រូវទៅអង្គុយកន្លែងអ្នកចាប់កន្សែងបានកន្លែងវិញដដែល ។

គេលេងតែរបៀបនេះរហូតដល់ពេលឈប់ ។ ជួនកាលអ្នកខ្លះមិនដែលបានឡើងលាក់កន្សែងនឹងគេម្តងសោះក៏មាន ព្រោះគេលាក់កន្សែងក្រោយខ្នងខ្លួន ខ្លួនមិនដឹង រវល់តែគេគក់ខ្នងបានរាល់ពេល ។

ល្បែងនេះ គេលេងដើម្បីហាត់ខ្លួនឲ្យមានស្មារតីរឹងប៉ឹង រហ័សរហួន ឲ្យមានប្រាជ្ញាវាងវៃ ហាត់ទម្លាប់ខ្លួនឲ្យចេះប្រុងស្មារតីជានិច្ច ។

※

※ ※

www.elibraryofcambodia.org

# ៦– ល្បែងឆ្មបត្រឡាប ឬ បោះឆ្មឡឹក

ល្បែងខ្មែរ មានច្រើនបែប ល្បែងខ្លះគេលេងតែក្នុងពេលថ្ងៃ ល្បែងខ្លះគេលេងតែក្នុងពេលយប់ខែភ្លឺ ល្បែងខ្លះគេលេងតែក្នុងពេលបុណ្យមានបុណ្យចូលឆ្នាំជាដើម ល្បែងខ្លះគេលេងមិនកំណត់ពេល ។

ល្បែងដែលលេងតែក្នុងពេលយប់ខែភ្លឺ ហើយមិនចាំបាច់មានបុណ្យទានអ្វីនោះ មាន ល្បែងឆ្មបត្រឡាប ឬ បោះឆ្មឡឹក ជាដើម ។ ល្បែងនេះ ជាល្បែងកំសាន្តសប្បាយ របស់ពួកកុមារកុមារីនៅគ្រប់ទិសម ជនបទនៃប្រទេសកម្ពុជា ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ :



www.elibraryofcambodia.org

របៀបលេង មុនដំបូង ពួកកុមារប្រុសស្រី ស្រុះស្រួលចិត្តបបួលគ្នាឲ្យមានចំនួនច្រើន រួចហើយគេចាត់ម្នាក់ឲ្យធ្វើម្ចាស់ត្រឡាច ប្តុះឡឹក ម្នាក់ទៀតឲ្យធ្វើអ្នកទិញ សល់ប៉ុន្មានគេឲ្យធ្វើត្រឡាច ប្តុះឡឹកទាំងអស់ ហើយអ្នកលេងទាំងនោះគេសំដៅទៅរកគល់ឈើ ឬដង្កត់អ្វីមួយ ឲ្យតែមានទំហំល្មមឱបបាន, ដោយហោចទៅសសរផ្ទះក៏បានដែរ ឲ្យតែជាទីវាលស្រឡះល្អ ។ កាលបានកន្លែងស្រួលបួលហើយ, ក្មេងម្នាក់ជាទី ១ ក្នុងបណ្ដាក្មេងដែលគេឲ្យធ្វើត្រឡាច ប្តុះឡឹកនោះ អង្គុយឱបដើមឈើ ឬសសរនោះទាំងជើងទាំងដៃ, ក្មេងម្នាក់ទៀតជាទី ២ អង្គុយឱបចង្កេះ យកជើងទាំងពីរដាក់លើភ្លៅក្មេងទី ១, ក្មេងទី ៣ យកដៃទាំងជើងឱបក្មេងទី ២ ដូចក្មេងទី ២ ឱបក្មេងទី ១ ដែរ ឯក្មេងដទៃទៀតក៏បន្តគ្នារហូតទាល់តែអស់ពួកក្មេងដែលត្រូវធ្វើត្រឡាចប្តុះឡឹក ។ ឯក្មេងម្នាក់ដែលគេឲ្យធ្វើជាម្ចាស់ត្រឡាចប្តុះឡឹកឈរធ្វើព្រងើយ ដើរទៅ ៗ ក្បែរក្មេងជាត្រឡាចប្តុះឡឹកទាំងនោះ ហើយក្មេងម្នាក់ទៀត ដែលគេឲ្យធ្វើជាអ្នកទិញមកសួរតម្លៃអ្នកលក់បីដូចជាគេទិញធម្មតា ។ តម្លៃគ្នាត្រូវរ៉ូវហើយក៏ឲ្យអ្នកទិញរើសតាមចិត្ត ។ អ្នកទិញក៏ដើរយកដៃគោះខ្នងក្មេងដែលអង្គុយឱបគ្នានោះ ។ គោះបណ្ដើរសួរបណ្ដើរថា ខ្ចីឬទុំ? ។ អ្នកបន្ត ៗ

www.elibraryofcambodia.org

ក៏ដើមទៅ  បេះតែឆ្លើយថាទី ១  លុះដល់អ្នកចុងថ្ងៃបំផុតទើបឆ្លើយថា ទុំ  រួចអ្នកទិញក៏បេះយកអ្នកដែលនៅចុងគេបំផុតនោះទៅ  ដោយខំប្រឹងទាញមែនទែន  ព្រោះអ្នកអង្គុយឱបគ្នាគេទាំងឱបចំកោងខ្លួនតែរៀងខ្លួន តាំងពីអ្នកខាងចុងរហូតអ្នកខាងគល់  រេចុះរេឡើង  ដោយអ្នកបេះប្រឹងទាញខ្លាំងពេក ។ អ្នកបេះក៏បេះប្រលេះបានមួយម្ដងដកបដល់អស់មនុស្ស ជួនកាលក៏បេះបាន ២-៣-៤ នាក់  តាមដែលអ្នកខាងដើមឱបជាប់  ឬមិនជាប់  បេះបានប៉ុន្មានយកមកដាក់ ១ ជុំ,  បើអ្នកទិញបេះមិនបាន  ដោយកម្លាំងខ្សោយជាងគេនោះ  ក៏វិលលេងសាជាថ្មីម្ដងទៀត ។ ឯអ្នកលក់អ្នកទិញត្រឡប់ទៅធ្វើជាអ្នកឱប  ហើយអ្នកឱបមុនក៏ប្ដូរទៅធ្វើជាអ្នកលក់អ្នកទិញវិញ ។ គេធ្វើដោយរបៀបនេះរហូតដល់ពេលឈប់លេង ។

ល្បែងនេះ  ជាកីឡារបស់ខ្មែរសម័យបុរាណ  សម្រាប់ហាត់ដៃហាត់ជើងឲ្យមានកម្លាំងពលំមាំមួន  ឲ្យមានសាច់ដុំល្អ  មានសុខភាពស្រួលបួល ។

※

※ ※

www.elibraryofcambodia.org

# ៧- ល្បែងប្រដល់មាន់

ល្បែងប្រដល់មាន់ ជាល្បែងមួយ របស់ពួកកុមារកុមារី ជំទង់ៗ នៅក្នុងកម្ពុជរដ្ឋ គេតែងលេងក្នុងវេលាយប់ ៗ សមាស-ភាពនៃអ្នកលេងល្បែងនេះ មានគ្នា ៤ នាក់ គឺប្រុសម្នាក់ធ្វើមាន់ឈ្មោល ស្រីម្នាក់ធ្វើមាន់ញី ប្រុសម្នាក់ស្រីម្នាក់ធ្វើជាអ្នកចាំឡើកមាន់ ៗ ពេលលេងប្រុសម្នាក់ស្រីម្នាក់ដែលធ្វើមាន់ចូលទៅនុនក្រោមទន្ទឹមគ្នា មួយបែរមុខទៅខាងជើង មួយបែរមុខទៅខាងត្បូង ៗ ឯប្រុសម្នាក់ដែលធ្វើជាអ្នកចាំឡើកចូលទៅឈរក្បែរមាន់ឈ្មោល មាន់ញីរបស់ខ្លួនចាំឡើកមាន់ខ្លួន ៗ

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ :



www.elibraryofcambodia.org

ពេលរៀបឲ្យមាន់ផល់គ្នា ម្ចាស់មាន់គេទះដៃស្រែកឡើង ថា «យើងបានគ្នាហើយ» ។ បន្ទាប់ពីម្ចាស់មាន់ស្រែក គូមាន់ក៏រៀបខ្លួនចូលទៅផល់ ដោយកាន់ដៃឡើងធ្វើបែបមាន់ទទះស្លាប ហើយដើរឱន ៗ ចូលទៅឈរជិតគ្នា មានអាការដូចផ្លូតផល់គ្នា តែមិនឲ្យប៉ះទង្គិចស្លាបឬប៉ះដៃគ្នាទេ គ្រាន់តែលើកដាក់ដៃទាំង ២ តាមចង្វាក់ពាក្យច្រៀងរបស់ម្ចាស់មាន់ប៉ុណ្ណោះ ។ ពេលនោះ ម្ចាស់មាន់គេច្រៀងឡើងថា «មាន់នាងទីរ៉ុយ ៗ ផល់ទីងមាន់នាងទល់ លោកឲ្យប្រផល រ៉ុយ ៗ មាន់យើងឈ្នះគេ» ។ កាលម្ចាស់មាន់ច្រៀងហើយ មាន់ទាំងពីរក៏លោតចូលទៅឈរកណ្ដាលវង់ ហើយលោតចេញមកវិញ ចេញមកហើយចូលទៅវិញទៀត ដោយធ្វើអាការទទះស្លាបដូចមុន ម្ចាស់មាន់ក៏ស្រែកច្រៀងដូចមុនម្ដងទៀត ។

មាន់ខាងណាមានអាការក្លៀវក្លា ស្វាហាប់ក្លាហាន ខ្លាំងពូកែជាងគេ ក្នុងវេលាផល់ គេទុកជាឈ្នះ ។ កាលបើមាន់ ១ គូមុន ដឹងឈ្នះចាញ់ហើយ ម្ចាស់មាន់គេឲ្យមាន់ផឹកទឹក គឺឲ្យផឹកទឹកត្នោត ឬឲ្យស៊ីបបរជាដើម ជាកំសាន្តសប្បាយ ហើយគេរៀបចំប្រផល់សាជាថ្មីទៅទៀត ។ គេលេងតែរបៀបនេះ រហូតដល់ពេលឈប់ ។

ល្បែងនេះ អាចរាប់ចូលក្នុងកីឡា សម្រាប់បង្ហាត់ក្មេងឲ្យមានទំលាប់ប្រកាន់នូវសេចក្ដីក្លាហានបាន ។

www.elibraryofcambodia.org

# ៨– ល្បែងគ្របមាន់(១)

ល្បែងគ្របមាន់ ជាល្បែងកំសាន្តមួយយ៉ាងរបស់ពួកកុមារកុមារីជំទង់ ៗ គ្រប់ភូមិ-ស្រុក ទូទៅទាំងប្រទេសកម្ពុជា ដែលតែងតែលេងនៅពេលទំនេរ ក្នុងវេលាយប់ខែភ្លឺ ។ អ្នកលេងមានស្រីមានប្រុស មានគ្នាតាំងពី ៤ នាក់ ឬ ១០នាក់ម្ខាងឡើងទៅ ។ របៀបលេងគេជ្រើសយកក្មេងប្រុសម្នាក់ស្រីម្នាក់ ក្នុងបណ្ដាពួកគេទាំង ២ នោះ មកគ្របសំពត់ឬក្រមា ឲ្យជិតខ្លួនតាំងពីក្បាលដល់ចុងជើង ដើម្បីកុំឲ្យស្គាល់ថានរណា ហើយគេឲ្យក្មេងពីរនាក់នោះ ក្រាបបែរមុខរកគ្នា គឺខាងប្រុសតំណាងមាន់ឈ្មោល ខាងស្រីតំណាងមាន់ញី ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ



១– ស្រុកខ្លះ គេហៅថា ល្បែងលាក់មាន់ ។

www.elibraryofcambodia.org

កាលក្រោយហើយគេឲ្យពួកខាងប្រុសម្នាក់គោះខ្នងមាន់ខាងស្រីឲ្យរងាវ មាន់ខាងស្រីរងាវថា "កិកកិកែកីត" ឡើង ដោយខំធ្វើសម្លេងឲ្យប្លែកពីធម្មតា ។ តែបើស្ដាប់សូរមិនបានគេអាចគោះឲ្យរងាវបានបីដង។ ពួកខាងប្រុសចាំស្ដាប់សម្លេងមាន់ខាងស្រីនោះ ហើយគេទាយតាមឈ្មោះមនុស្សស្រីដែលគេស្គាល់, ទាយហើយគេបើកគម្របឡើង បើត្រូវ គេយកមាន់នោះមកទុកជារបស់គេ រួចហើយខាងស្រីគោះមាន់ខាងប្រុសឲ្យរងាវម្ដង ៗ មាន់ខាងប្រុសរងាវថា "កិកកិកែកីត" ដូចគ្នា ។ ពួកខាងស្រីចាំស្ដាប់សម្លេងមាន់ខាងប្រុសនោះ ហើយគេទាយតាមឈ្មោះមនុស្សប្រុសដែលគេស្គាល់ បើខាងស្រីទាយត្រូវ ខាងប្រុសគេយកមាន់ខាងស្រីដែលគេយកទៅនោះមកសងស្រីវិញ តែបើខាងស្រីទាយខុស ខាងប្រុសគេយកមាន់ខាងស្រីនោះទៅទៀត ។

ការទាយសម្លេងមាន់ ស្រេចលើខាងណាទាយត្រូវច្រើន គេបានមាន់ច្រើន ខាងណាទាយខុសច្រើន ត្រូវបង់ខាតមាន់ច្រើនដែរ ។ គេធ្វើរបៀបនេះទាល់តែម្ខាង ៗ អស់មាន់ទាំងអស់ ឬអស់មាន់ច្រើនជាង គេទុកជាចាញ់ ខាងណាបានមាន់ច្រើន គេទុកជាឈ្នះ ហើយគេរៀបចំលេងថ្មីឡើងវិញ គេលេងតែធ្វើរបៀបនេះ ដរាបដល់ពេលណាដែលគេសន្មតគ្នាថាឈប់ ទើបលែងលេង ៗ ។

www.elibraryofcambodia.org

ល្បែងនេះ ជាល្បែងកំសាន្តមួយយ៉ាង សម្រាប់កុមារកុមារី ជំទង់ៗ លេងតាមសប្បាយ ដែលជាល្បែងហាត់បញ្ញា ហាត់គំនិត ឲ្យប៉ិនប្រសប់ខាងស្តាប់ ខាងកាត់ប្រមាណតម្រូវតាមសម្លេងរបស់មនុស្ស ។

※

※ ※

www.elibraryofcambodia.org

# ៩- ល្បែងបិទពួន

ល្បែងបិទពួន ជាល្បែងមួយយ៉ាងដែលពួកកុមារកុមារីជំទង់ ៗ តែងលេងកំសាន្តសប្បាយនៅពេលក្រីខែភ្លឺ ។ ល្បែងនេះគេលេងគ្មានកំណត់ខែណាថ្ងៃណាទេ នៅខែណា ថ្ងៃណាក៏បាន ឲ្យតែមានពេលល្ហែ ហើយគ្មានកំណត់ចំនួនមនុស្សឡើយ ។ វិធានការនៃល្បែងនេះ គឺពួកម្ខាងអ្នកពួន ពួកម្ខាងទៀតអ្នកដើររក, កាលរកឃើញគេដេញចាប់ពួកអ្នកពួន ដើម្បីញៀច ( មួលស្លឹកត្រចៀក ) ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



www.elibraryofcambodia.org

របៀបលេង, មុនដំបូង គេបបួលកុមារកុមារីដែលមានអាយុស្រ-
បាល ១ គ្នា ឲ្យបានច្រើនប្រមាណ ៨ ឬ ១០ នាក់ឡើងទៅ ស្រេចតែ
មានគ្នាតិចឬច្រើន បែកជាពីរផ្នែកស្មើគ្នា ស្រីម្ខាងប្រុសម្ខាង ឬលាយ
ចម្រុះគ្នាទាំងស្រីទាំងប្រុស ឬក៏សុទ្ធតែប្រុស សុទ្ធតែស្រីក៏បាន ។ គេ
កំណត់កន្លែងណាមួយ ដែលមានភាពដីស្រឡះ ឲ្យឈ្មោះថា "ទី"
ហើយគេឲ្យពួកម្ខាងទៅពួនទៅទីដទៃ គឺត្រូវពួនរបៀបណាកុំឲ្យពួកម្ខាង
ទៀតគេឃើញបានដោយងាយ ពួកម្ខាងទៀតឈរធ្មេចភ្នែកឬបិទភ្នែកនៅ
ក្នុងទី ។ គ្រាឃាមរបស់ពួកនេះ នៅត្រង់ធ្មេចភ្នែក គឺគេសន្យាគ្នាថា
អ្នកណាលួចមើលពួកគេអ្នកពួន ឲ្យដឹងថាគេពួនត្រង់នេះត្រង់នោះ នឹងត្រូវ
ស្អុយភ្នែក ។ ចំនួន ២-៣ នាទី ទើបពួកអ្នកនៅក្នុងទីបើកភ្នែកឡើង
ស្រែកថា "បើកគ្រួបបាយ កំបាយរក អ្នកណាមិនមក អញរក
ឃើញ" ហើយក៏ចាត់ម្នាក់ រើសរកអ្នកណាមានមាឌមាំបន្តិច ក្នុងបណ្ដា
ពួកអ្នកឈ្លាំទីនោះ ឲ្យនៅចាំទីការពារ កុំឲ្យពួកអ្នកទៅពួនរត់មកចូលទី
បាន សល់ប៉ុន្មានឲ្យដើររកគ្រប់ទីកន្លែងដែលកំបាំង ៗ ។ បើអ្នកចាំណា
មួយឃើញអ្នកពួនណាម្នាក់ក៏នាំគ្នាដេញចាប់ញៀច បើដេញញៀចបាន
ឈ្មោះថាស្អុយ បើមិនបាន អ្នកពួននោះរត់ចូលទីបាន ឈ្មោះថាបាន
រួចខ្លួន មិនត្រូវដេញញៀចគេទៀតទេ, ប៉ុន្តែអ្នកពួននោះ បើចូលទី

www.elibraryofcambodia.org

ហើយត្រូវស្រែកឲ្យខ្លាំងៗថា "ចូលទី" បើមិនស្រែកទេគេមានអំណាចញៀបបានទៀត ។ លុះអ្នកដើររក រកឃើញពួកអ្នកពួនអស់ហើយ ឬបើមិនទាន់ឃើញអស់គេខំដើររកឲ្យទាល់តែឃើញ ពោះបើញៀបបានក៏នោយមិនបានក៏ដោយ មកជួបជុំហើយ គេក៏និយាយប្រាប់អ្នកទាំងអស់គ្នា •(ទាំងពីរផ្នែក) ថា ពួកគេញៀបបានប៉ុណ្ណោះនាក់ប៉ុណ្ណោះនាក់តាមដែលគេញៀបបាន រួចហើយពួកអ្នកនៅចាំទីមុននោះទៅពួនវិញ, ឯពួកអ្នកពួនមុនត្រូវនៅក្នុងទី ហើយដើររកគេ ផ្លាស់ប្តូរគ្នាតែរបៀបនេះរហូតដល់ពេលឈប់លេង ។

ក្នុងការផ្លាស់ប្តូរគ្នានេះ គឺទៅពួនម្តងមួយផ្នែក រួចហើយបើពួកខាងម្ខាងញៀបគេបាន ៣-៤ នាក់ ដល់ពួកម្ខាងទៀតញៀបគេវិញបានតែ ២-៣ នាក់ ពួកនោះ ឈ្មោះថាចាញ់គេ ។

តាមរបៀបអ្នកស្រុកខ្លះ គេលេងប្លែកពីនេះបន្តិច គឺគេប្រមូលអ្នកស្ម័គ្រលេងទាំងប៉ុន្មានមកឈរជែកជង់ ហើយម្នាក់ផ្តើមសូត្រថា "ត្រៃត្រៃ ត្រៃត្រង់" ឬថា "កាច់ស្លឹកចុះស្បៀ សំដីល ខែចែត្រពេញបូណ៌លោ-ឲ្យលេងពួន លេងខែណាលេងខែជូនព្រះ កាច់សន្ទុះមហាវង់ដែង អញ្ជើញអញ្ចាក់ អញ្ជើញចង្វាក់ អញ្ចឹកអង្គុង អំពង់អំពួន ប្រពន្ធចៅហ្វាយ" ។

www.elibraryofcambodia.org

ឲ្យឈ្មោះថា "គោយ" បែកចេញជាពីរផ្នែកដែរ គេហៅថា គោយដាំមួយពួក គោយបោះមួយពួក ៗ គោយមួយពួក ៗ មានចំនួន ៣ ឬចំនួន ៥ គឺថាបើដាំគោយ ៣ ក៏បោះគោយ ៣, បើដាំគោយ ៥ ក៏បោះគោយ ៥ តាមចំនួនអ្នកលេងមានគ្នាតិចឬច្រើន ៗ ដែលហៅថាគោយដាំ គឺគេដាំភ្ជាប់នៅទីដីមានជួរបែកកន្ទែកចេញពីគោយកណ្ដាលមួយដែលហៅថា "ម៉េគ្វាន ឬ កន្ទាន" មួយឬពីរខាងស្ដាំ មួយឬពីរខាងឆ្វេងមានសណ្ឋានដូចក្អែកទឹកហើរ ដែលឲ្យមេខ្សែល់មួយនាំមុខ ហើយក្អែកទាំងប៉ុន្មានបែកគ្នាជាពីរជួរបញ្ឆៀង ៗ គ្នាពីក្រោយ ៗ រីឯគោយបោះ គឺគោយទាំងឡាយដែលគេកាន់យកទៅទីហើយបោះក្ដីធ្វើអ្វីគ្រប់បែបទៀតក្ដីសំរាប់លេងគោយដាំទាំងប៉ុន្មាននោះ ៗ ត្រង់រណ្ដៅតូច ៗ ដែលឆៀលដីយកកន្លែងដាំគោយឲ្យជាប់នោះ គេហៅថា "រន្ធ ឬ រន្ធគោយ" ៗ គេកំណត់កន្លែងមួយពីមុខគោយដាំប្រមាណជា ៣ ឬ ៤ ម៉ែត្រ សន្មតហៅថា "ទី" គឺជាទីដែលគេត្រូវទៅបោះឬទៅធ្វើបែបអ្វីមួយពីត្រឹមនោះតម្រង់មកគោយដាំវិញ ៗ អ្នកដែលត្រូវឡើងមុន គឺបានទៅបោះពីទីមុនគេនោះសម្រេចលើការព្រមព្រៀងគ្នា, ជាធម្មតា គេច្រើនតែអនុញ្ញាតឲ្យពួកអ្នកខ្សោយជាងមានសិទ្ធិទៅបោះមុនគេ ទុកដូចជាតទីឲ្យដែរ ៗ ឯការទាញឈ្មោះស៊ីសងត្រង់នរណាធ្វើត្រូវគោយដាំចប់សព្វគ្រប់មុនគេ គឺគ្រប់បែបគ្រប់

www.elibraryofcambodia.org

ថ្នាក់ដែលរបៀបលេងអង្គញ់តម្រូវឲ្យមានប៉ុន្មាន ៗ ប៉ុន្តែគេច្រើនសន្មតគ្នា បន្ទុមឲ្យអ្នកបាញ់ធ្វើ ៣ ឬ ៤ ក្តារសិន ហៅថា "តាម" ដូច្នេះ បានជាមុននឹងលេង គេសន្មតគ្នាថា តាមប៉ុន្មានក្តារ ? បើគេសម្រេចគ្នាថាប៉ុន្មាន ៗ ដល់ទីបំផុតត្រូវតែ "តាម" ប៉ុណ្ណោះក្តារសិន ៗ បើផុតកំណត់ហើយទៅ តែមិនបានធ្វើត្រូវអស់ទៀតនោះ ទើបទុកជាចាញ់ ហើយពួកខាងឈ្នះត្រូវដោះពួកខាងចាញ់ តាមចំនួនដែលគេសន្យាគ្នា ឧបមាថា គេសន្យាថាកោយមួយដោះ ១០ ដូច្នេះអ្នកណាកាន់កោយបោះមួយ បើឈ្នះត្រូវបានដោះគេ ១០ តែបើចាញ់ក៏ត្រូវឲ្យគេដោះ ១០ ដែរ ។

ល្បែងនេះ មានលក្ខខណ្ឌតឹងរ៉ឹងណាស់ បើធ្វើខុសបទវិន័យណាមួយ នឹងត្រូវទទួលពិន័យភ្លាមមួយរំពេច ៗ លក្ខខណ្ឌទាំងនេះ យើងនឹងបរិយាយក្នុងរបៀបលេងខាងក្រោមនេះ ។

ល្បែងអង្គញ់ ចែកចេញច្រើនជាន់ថ្នាក់ជាសង្កាត់ ៗ មាន ៖

១– ញោះ (កាន់បោះមកពីទីតម្រង់កោយជា)

២– ស៊ីគោល (បាញ់ដោយម្រាមដៃដាក់លើក្បាលជង្គង់)

៣– ស៊ីប៉ោរត (បាញ់ដោយម្រាមដៃដាក់ផ្ទាល់នឹងដី)

៤– ត្រកង (ប្រមៀលអង្គញ់មកពីទី)

www.elibraryofcambodia.org

## ៤– បាក់ខ្លុក (ដាក់អង្គញ់លើខ្នងជើងដើរបីជំហាន)

### ៦ ប្រោះដោះ (បោះសម្រេចជាចុងក្រោយបំផុត)

របៀបលេង ក្នុងសង្កាត់និមួយ ៗ មានដូចតទៅ ៖

ថ្នាក់ទី ១ បោះ= ពួកអ្នកដែលត្រូវឡើងទៅបោះ គេបោះតម្រង់ទៅកោយដែលដាំណាមួយ, កាលបោះទៅត្រូវកោយដាំនោះហើយ កោយនោះក៏ខ្ទាតចេញពីរន្ធទៅ កោយបោះក៏នៅក្នុងរន្ធកោយដាំ, ហើយអ្នកដាំទុះកោយបោះនោះបន្ថែមទៀត យ៉ាងនេះគេហៅថា "ស្អុយ" ។ បើបោះត្រូវកោយណាមួយហើយ ដល់បោះកោយ ១ ក្រោយទៅត្រូវកោយដដែលទៀតគេហៅថា "ម៉ាយ" ។ បើអ្នកបោះប្រព្រឹត្តខុសវិន័យតាំងនេះហើយ ត្រូវអ្នកដាំទៅបោះ អ្នកបោះមកដាំវិញម្តង ។ កាលណាបោះទៅត្រូវកោយដែលដាំដួលទាំងអស់រួចហើយ អ្នកបោះត្រូវចាប់បន្តធ្វើស៊ីគោលតទៅទៀត ។

ថ្នាក់ទី ២ ស៊ីគោល= កាលបើបោះត្រូវអស់ហើយ គេយកកោយរបស់គេដើរសំដៅទៅ "ទី" ហើយអង្គុយច្រហោងរុញក្បាលជង្គង់ម្ខាងទៅមុខបន្តិច យកកោយដាក់លើក្បាលជង្គង់នោះ ផ្ទាត់កោយដោយមេដៃប្តូចផ្អុលដែតម្រង់ទៅកោយដាំណាមួយ ។ បើកោយផ្ទាត់ទៅនោះធ្លាក់ជិត

www.elibraryofcambodia.org

កោយដាំពេកប្រមាណជា ១ ចអាម ឬកន្ទះចំអាមនោះ, អ្នកស៊ីគោលគេសួរអ្នកដាំថា "វ៉ឹផ ឬណាប់?" បើអ្នកដាំឆ្លើយថា "វ៉ឹផ" អ្នកស៊ីគោលត្រូវវាស់ជាចំអាម ដោយយកមេដៃដាក់លើកោយរបស់ខ្លួនចន្ទុលដៃវ៉ៃកោយដាំឲ្យផ្លូលតែម្តង ៗ បើអ្នកដាំឆ្លើយថា "ណាប់" អ្នកស៊ីគោលគេលើកកោយរបស់គេគប់ទៅកោយដាំនោះឲ្យផ្លូលតែម្តង ៗ ដូចនេះ កោយដែលស៊ីគោលធ្លាកជិតពេកនោះ គេឲ្យឈ្មោះថា "វ៉ឹផ- ណាប" ៗ បើកោយដែលស៊ីគោលទៅហើយធ្លាកឆ្ងាយពីកោយដា ជាង ១ ចអាម នោះ អ្នកស៊ីគោលគេត្រូវលុតជង្គង់ ហើយយកកោយនោះមកដាក់លើក្បាលជង្គង់ផ្ទាត់តម្រង់ទៅកោយដាំបន្តទៅម្តងទៀត ទាល់តែអស់កោយរបស់ខ្លួន ។ បើកោយស៊ីគោលនោះរត់ទៅប៉ះគ្នា ដូចជាកោយស៊ីគោលទៅមុនធ្លាក់ត្រង់កន្លែងណាមួយហើយ កោយទៅក្រោយរត់ទៅប៉ះកោយមុននោះ ដល់ពេលអ្នកបាញ់គេទៅបាញ់ម្តងទៀតនោះ អ្នកដាំគេត្រូវពិន័យដូច្នេះ គឺកោយមុនគេឲ្យផ្ទាត់ដោយស្រលៀនក្អែកម្ខាង គឺឲ្យធ្លុចក្អែកម្ខាង ឯកោយក្រោយគេឲ្យផ្ទាត់ដោយខ្ទាក់ក្អែក គឺឲ្យធ្លុចក្អែកទាំងសងខាង ។. ដូច្នេះ ទើបគេឲ្យឈ្មោះកោយ ២ នេះថា កោយខ្ទាក់ទិនស្រលៀនតាមទណ្ឌកម្មដែលគេពិន័យ ។ បើស៊ីគោលដូចបានរៀបរាប់មកនេះ ត្រូវ

www.elibraryofcambodia.org

កោយនាំផ្លូវអស់ហើយ គេត្រូវធ្វើស៊ីប៉ារេតតទៅទៀត ៗ

ថ្នាក់ទី ៣ ស៊ីប៉ារេត= ពួកអ្នកស៊ីគោលនោះ កាលបានធ្វើស៊ីគោលរួចហើយ គេនាំគ្នាយកកោយទៅដាក់ផ្ទាល់នឹងដី ហើយបាញ់ដោយម្រាមដៃមួយម្តង ៗ តម្រង់ទៅគេកោយនាំ រហូតដល់អស់កោយ ៗ ការពិន័យមាន វ៉ែ ណាប់ ស្រលៀន ខ្ទាក់ របៀបដូចស៊ីគោលដែរ ខុសគ្នាតែត្រង់ស៊ីគោលគេធ្វើលើក្បាលជង្គង់, ចំណែកស៊ីប៉ារេតដាក់កោយផ្ទាល់នឹងដីតែប៉ុណ្ណោះ ៗ លុះធ្វើស៊ីប៉ារេតរួចហើយ គេធ្វើត្រកង់តទៅទៀត ៗ

ថ្នាក់ទី ៤ ត្រកង់ ឬ ត្រឡង់កង់= ក្រោយដែលធ្វើស៊ីប៉ារេតត្រូវអស់ហើយ គេចាប់ធ្វើបន្តទៅទៀតគឺត្រកង់ ៗ ត្រកង់នេះ គឺគេប្រមៀលកោយ (គ្រាប់អង្គុញ) ឲ្យរមៀលដូចបរកង់ ហេតុនេះបានជាគេហៅថា "ត្រកង់ ឬ ត្រឡង់កង់" ៗ ត្រកង់មានពីរបែប, គេយកបែបណាមួយមកលេងក៏បានតាមតែគេណាត់គ្នា ហៅថាត្រកង់ទប់និងត្រកង់ធា ៗ ត្រកង់ទប, គឺគេប្រមៀលកោយទៅហើយត្រូវរត់តាមទៅយកដៃខ្ទប់ឲ្យទាន់មុនកោយនោះដួល ហើយមិនឲ្យហួសមេក្វានផង តែបើទប់មិនទាន់បណ្តោយឲ្យកោយដួលសៀមខ្ទង់ ឬទប់ដៃតែមិនបានយកដៃខ្ទប់ឲ្យជិតល្អ

www.elibraryofcambodia.org

លើកោយនេះទេ នោះគេទុកជាស្អុយមិនបានការ, ពួកខាងម្ខាងត្រូវឡើងជើងម្តង ៗ បើកោយនោះរត់លឿនពេកទៅហួសមេក្វាង ឬមួយក៏ទង្គិចផ្លូលកោយដាំណាមួយក៏ទុកជាស្អុយ ត្រូវគេ "ឡើង" ដែរ ៗ ឯត្រកងធាវិញពុំពិបាករត់តាមខ្ទប់ទេ តែត្រូវមានវិន័យមិនឲ្យហួសមេក្វាង ទង់ទង្គិចកោយដាំឡើយ ៗ របៀបត្រកង ក៏ដូចជាស៊ីគោល ឬស៊ីប៉ារេតដែរ គឺធ្វើបានពីរជំណាក់ គឺត្រកងពីទីទៅដល់ត្រង់ណាហើយ អាចតាមទៅបាញ់ដោយម្រាមដៃផ្ទាល់ទីង៍ដីតម្រង់ទៅកោយដាំម្តងទៀត ៗ ប្រសិនជាមានរះផ្លូលកោយដាំម្តង ២ ឬ ៣; ម៉ាយ; នឹងមិនផ្លូលកោយដាំនោះ, គ្រាន់តែដើរក៏ត្រូវទទួលបទពិន័យដូចមុនៗ ដែរ ៗ

ឋាក់ទី ៥ បាក់ខ្វែក= ចាក់ខ្នងអានរបៀបប្លែកពីមុន ១ គឺគេឈានមួយជំហានពីគំនូសទី(១) រួចយកអង្គញ់ដាក់លើខ្នងជើង ហើយឈានពីរជំហានទៅមុខទៀត ទើបលោសចុងជើងគ្រវាត់គ្រាប់អង្គញ់ទៅឲ្យត្រូវកោយដាំ ៗ កាលណាមិនត្រូវក៏ស្អុយកោយបោះចោលទៅ កាលណាត្រូវ អាចយកកោយដដែលនោះមកធ្វើសាជាថ្មីបានម្តងទៀត ៗ ប្រសិនជាដាក់កោយលើខ្នងជើងហើយឈានពុំទាន់ដល់កោយដាំ ស្រាប់

---

១ - ក្នុងកាលគេមិនឈានជំហាន ដាក់កោយពីទីមកតែម្តងក៏មាន កាលណាគេជាជើងកើតផ្លូវញ ។

តែជ្រុះក្រោយទៅ នោះគេទុកជាបាក់កលៀនអណ្ដាត គឺគេឲ្យយកទៅធ្វើម្ដងទៀតតែឲ្យអ្នកនោះងើយកឡើងលើលៀនគណ្ដាត មិនឲ្យមើលទៅក្រោយជាទេ គឺថាធ្វើប្រថុយៗ តាមស្មាន ។ ចាក់ខ្វែកឥតធ្វើពីរជំណាក់ គឺតាមទៅផ្ទាត់បាញ់ទៅផិតក្រោយដាដូចត្រកង ស៊ីគាល-ស៊ីប៉ារ៉ែតទេ គេធ្វើយកត្រូវពីទីតែម្ដងៗ កាលបើមានរះ, ម៉ាយ, កប់ គេពិន័យដូចធ្វើត្អើ ៗ ពីមុខមកដែរ ។

ថ្នាក់ ទី ៦ បោះជោះ= បោះជោះក៏ដូចជាបោះពីដំបូងដែរ វិន័យគ្រប់បែបគ្រប់យ៉ាងដូចគ្នាទាំងអស់សព្វសារ ។ គិតទៅបោះជោះនេះ ហាក់ដូចជាគ្រាន់តែជាវិញ្ញាសាមួយសម្រាប់វង់ចាំ ពួកខាងយើងជាង ឲ្យបានទុកាសដេញតាមតែប៉ុណ្ណោះ ។ បានជាហៅថា បោះជោះ ព្រោះបន្ទាប់តែពីបោះនេះទៅ ត្រូវបានជោះហើយ (គ្រាន់តែវង់ចាំឲ្យគេតាមប៉ុន្មានក្តារ ដែលបានសន្មតមកតែប៉ុណ្ណោះ) ។

របៀបជោះ គឺគេយកអន្ទាញ់មួយផ្ទាប់ទៅដលក្បាលជន្ទល់ ហើយយកអន្ទាញ់មួយទៀតវាយជោះពីលើកប់ចំនួនតាមដែលគេត្រូវជោះ ។ ធ្វើបែបនេះហៅថា "ជោះបាយត្រជាក់" ។ មួយបែបទៀតហៅថា "ជោះបាយក្ដៅ" របៀបនេះគេផ្គួបអន្ទាញ់ពីរតម្រួតគ្នា គឺមួយផ្ដេកមួយ

បញ្ឈរ ហើយផាះខ្ទាំង ៗ ទៅលើក្បាលដង្គន់ មួយ ៗ ឡើងក្របាប សាច់ ទំពាំងគែអស់ចំនួន ៣០-៤០ សឹងតែហើបក្បាលដង្គន់តែម្តង ៗ ជួនកាលគេយកបំពង់ឫស្សីមកគោកក្បាលដង្គន់ ធ្វើជាជាះជំនួសគ្រាប់អង្គញ់ក៏មាន ៗ

ឯឈ្មោះពិធីដែលប្រើក្នុងល្បែងអង្គញ់នេះ មាន ៩ បែប ៖

១- ស្ទួយ (គឺធ្វើខុស ទុកកាយនេះជាអសារបង់)

២- ម៉ាយ (ត្រូវម្តងហើយ ត្រូវដដែលម្តងទៀត)

៣- វ៉ះ (គោយបោះមួយ ត្រូវគោយជាំម្តងពីរ)

៤- ដំដើ (គោយបោះតែប៉ះគោយជាំឲ្យរេធ្វើ មិនដួល)

៥- ស្រលៀង-ខ្ទាក់ (ព្រោះគោយបោះទង្គិចគ្នា)

៦- វ៉ឹង-ណាប់ (គោយបោះជិតគោយជាំពេក)

៧- បាក់កលៀនអណ្តាត (ចាក់ខ្វែកផ្ទាត់គោយកណ្តាលចំ)

៨- កប់ទ្រះ (គោយជាំខ្ទាតចេញ គោយបោះនៅក្នុងរន្ធជាំ)

៩- ហ្លួសមេដំបូល (សម្រាប់ត្រគង កុំឲ្យហួសមេក្លោង)

បទពិធីលើកហុសទាំងអស់នេះ មិនជាការធ្ងន់ពិបាកប៉ុន្មានទេ មានកំហុសខ្លះគេគ្រាន់តែ "ឡើង" គឺគេទុកការនេះជាអសារបង់ ត្រូវ

www.elibraryofcambodia.org

ផ្ទេរឲ្យពួកម្ខាងទៀតឡើងទៅធ្វើម្តង ដូចយ៉ាងឈ្លើយ រ៖ កប់ទះ ជាដើម ប៉ុន្តែទោះជាត្រូវ "ឡើង" ក្តី ក៏លើកក្រោយគេអនុញ្ញាតឲ្យពួកនេះចុះជាធ្វើត្រូវទាំងអស់នោះដែរ ។ ឯបទពិន័យផ្សេងទៀតក៏គ្រាន់តែជាក ទណ្ឌកម្មឲ្យលំបាកក្នុងការធ្វើតែប៉ុណ្ណោះ ពុំមានចាត់ទុកឲ្យក្រោយនោះស្អុយភ្លាម ៗ ទេ ។ ដូច្នេះ បទពិន័យគ្រាន់តែឲ្យបានសប្បាយ បានយូរបន្តិចប៉ុណ្ណោះឯង ។

## សេចក្តីបញ្ជាក់ :

គ្រាប់អង្គញ់ដូចគ្នានេះ គេអាចយកទៅលេងជាល្បែងមួយទៀតហៅថា "លេងគោល" ។ គឺថា គេយកកោយដាំប្រាំដែរ ដាំដង្ហែជាមួយជួរ ហើយមានគូសមួយដាក់ខ្វែងសន្ទូត ដាក់កោយបោះប្រាំដែរ តែដាក់ផ្ទាល់នឹងដី ។ គេយកជើងកៀស គឺជើងឆ្វេងឈរស្បៀមលូកទៅមុខ, ជើងស្តាំថយមកក្រោយ ចុចកែងឲ្យជាប់ទៅនឹងដី ហើយចុងម្រាមឆ្កើសយ៉ាងខ្លាំង ឲ្យកោយរត់ទៅត្រូវកោយដាំម្តងមួយ ៗ ទាល់តែអស់ បើកោយណាមិនបានត្រូវកោយដាំទេ គេទុកជាស្អុយ តែបើបានត្រូវគេឲ្យត្រឡប់យកមកគោល ( ឆ្កើសចុងម្រាមជើង ) បានម្តងទៀត ។ ពួកខាងណាធ្វើត្រូវអស់មុន ឈ្មោះថាឈ្នះ អាចផោះអ្នកចាញ់បាន ។

www.elibraryofcambodia.org

របៀបលេងគ្រាប់អង្គញ់មួយយ៉ាងទៀត គេហៅថា " បាញ់វង " គឺមានអ្នកលេងពីរពួក ៗ ពួកម្ខាង ៗ មានកោយដប់រៀងខ្លួន គឺសម្រាប់ដាំប្រា សម្រាប់បាញ់ប្រាំ ៗ គេដាជួរតម្រៀបគ្នាម្ខាងម្នាក់ ហើយយកកោយបាញ់ បាញ់ទៅខាងពួកបរបក្ខម្ខាងម្នាក់ ខាងណាបាញ់រលំរបស់ពួកខាងគេអស់មុន ឈ្មោះថាឈ្នះ បានដាះគេ ឯបាញ់នេះ គឺឈរបត់ក្បាលជង្គង់ម្ខាង ដាក់កោយលើក្បាលជង្គង់បាញ់ទឹងម្រាមដៃតម្រង់ទៅកោយដាំតែម្តង ៗ

ល្បែងអង្គញ់ អាចរាប់ចូលក្នុងពួកកីឡា ហាត់ដៃឲ្យត្រង់ ហាត់ភ្នែកឲ្យវៃ ហាត់ស្មារតីឲ្យមូលបាន ៗ

※

※ ※

www.elibraryofcambodia.org

# ១១- ល្បែងគោះពញាក់ ឬ ទះពញាក់

ល្បែងគោះពញាក់ និង ទះពញាក់ ជាល្បែងមួយយ៉ាង របស់មនុស្សជំទង់ៗ ឬចំណាស់ៗ ដែលត្រូវការលេងក្នុងវេលាថ្ងៃ នៅពេលមានបុណ្យទាន ពេលមង្គលការ ពេលចូលឆ្នាំថ្មី ឬក៏ពេលទំនេរ ។

ល្បែងនេះលេងបានទាំងប្រុសទាំងស្រី ។

គោះពញាក់មានអ្នកលេងតែម្នាក់, ឯទះពញាក់មានពីរនាក់ ។

របៀបគោះពញាក់៖ មុនដំបូងបង្អស់ អ្នកលេងគេអង្គុយពែនភ្នែន លើកដៃប្រណម្យសំពះគ្រូ ឬសំពះព្រះ ហើយលាដៃទាំងសងខាង ហាមាត់ចំហ ដៃឆ្វេងទះថ្ពាល់ស្តាំ ដៃស្តាំទះថ្ពាល់ឆ្វេង ញាក់ចិញ្ចើម ក្តក់ ៣ ដង ងាកចុះងាកឡើង ហើយចេះតែក្តក់ឲ្យឮប៉ែសៗតៗទៅ តាមបន្ទាក់គោះ ៥ ថ្នាក់ គឺ ទី ១ គោះដៃ, ទី ២ គោះថ្ពាល់, ទី ៣ គោះក្រោមបង្ការ, ទី ៤ គោះពោះ, ទី ៥ គោះភ្លៅទាំងសងខាង ។

www.elibraryofcambodia.org

លុះគោះគ្រប់ទាំង ៤ ថ្នាក់ហើយ គេចាប់គោះពីទី ១ មកវិញ សាចុះសាឡើងរឿយ ៗ ដើម្បីឲ្យពួកអ្នកទស្សនា កើតសេចក្ដីរីករាយ សប្បាយផាំក្សាន្ត ។

របៀបទះញាក់= មានសកម្មភាព ដូចរូបភាពនេះ :



ល្បែងនេះ ដំបូងបង្អស់ អ្នកលេងគេអង្គុយតែទក្មួន ទល់មុខគ្នាពីរនាក់ ដៃទាំងបួនផ្គុំគ្នា រួចហូតចេញពីគ្នាមកវិញ(១) ទើបទះដៃខ្លួនឯងមួយផូនម្នាក់, ទះភ្លៅខ្លួនឯងទាំងសងខាង, វិលមកទះដៃរៀងខ្លួនមួយផូនម្នាក់ទៀត ហើយទះដៃឆ្វេងផ្ទប់គ្នាពីម្នាក់ទៅម្នាក់ រួចទះដៃខ្លួនឯងមួយផូនទៀត ទើបលូកដៃស្ដាំទៅទះផ្ទប់គ្នាទៀត ។ គេធ្វើតែរបៀបនេះឡើងតែញាប់ឡើង ៗ នរណាភាន់ដៃទះមិនទាន់ គេទុកជាចាញ់ ។

១— របៀបផ្គុំដៃគ្នានេះ គេធ្វើតែម្ដងដំបូង, ឯលំដាប់តទៅ មិនបាច់ទេ ។

www.elibraryofcambodia.org

បែបនេះគេហៅថា " ពញាក់ញី " រីឯពញាក់ឈ្មោល គេសង្ខេបផាន់នេះ គឺទះក្បាលតែម្តងដំបូងប៉ុណ្ណោះ លុះលំដាប់តៗទៅ គ្មានទះក្បាលទៀតទេ ។

ល្បែងនេះ កប់ចូលក្នុងវិធីហាត់ប្រាណបាន ដែលនាំឲ្យដៃមានសាច់ដុំ ឲ្យដៃរហ័សរហួន នឹងឲ្យក្មេងវៃចេះសង្កេតហេតុការណ៍ផ្សេងៗ ។

※

※ ※

# ១២- ល្បែងគោះត្រឡោក

ល្បែងគោះត្រឡោក ជាល្បែងមួយ យ៉ាងរបស់មនុស្សប្រុសធំៗ កម្លោះៗ ឬប្រុសចំណាស់ៗ ដែលគេលេងក្នុងពេលណាក៏បាន តែគេច្រើនតែត្រូវការលេងក្នុងពេលលើកជំនូន-ស៊ីស្លា ឬមង្គលការកូន គឺពេលហែកូនប្រុសទៅជូនជំនូន ឬទៅចូលរោងនៅផ្ទះខាងស្រី, ក្នុងពេលនោះ គេតែងរកអ្នកចេះគោះត្រឡោក មកលេងជាកំសាន្ត ។

មនុស្សអ្នកលេងមានតែម្នាក់១ ៗ មុខទីលេង. គេយកត្រឡោកល្អ ៗ ២ ទំហំប៉ុនគ្នា មកកាន់នៅដៃស្តាំ ១ ឆ្វេង ១ ហើយគេអង្គុយ ឬឈរ គោះប្រជល់គ្នាតាមចង្វាក់ មាន ៧ គឺ :

ទី ១ គោះលើក្បាល

ទី ២ គោះខាងមុខ

ទី៣ គោះខាងក្រោមក្លៀកស្តាំ

ទី៤ គោះខាងក្រោមក្លៀកឆ្វេង

ទី ៥ គោះខាងក្រោមជើងស្តាំ

www.elibraryofcambodia.org

ទី ៦ គោះខាងក្រោមជើងធ្មេង

ទី ៧ គោះខាងក្រោយខ្នង

សកម្មភាពរបស់អ្នកគោះបែបអគ្គុយ ដូចក្នុងរូបភាពនេះ :



លុះគោះគ្រប់ ៧ ថ្នាក់ហើយ គេចាប់គោះពីទី ១ សាជាថ្មីឡើងទៀត តាមលំដាប់ហូរហែទៅ ៗ

បើគោះបែបឈរ គេគោះបណ្ដើរ ដើរបណ្ដើរ ច្រៀងបណ្ដើរ តាមបទ ឬចំនុកដែលគេបេះ ៗ នៅពេលហែកូនកម្លោះទៅស្ដីដណ្ដឹង ឬទៅចូលរោងការ ឬនាំកូនក្រមុំចុះពីផ្ទះទៅចូលរោងខាងប្រុស គេតែង

www.elibraryofcambodia.org

ដោះបែបឈរ, គឺអ្នកដោះត្រឡោក គេឈរបេរកាំភ្លើងដាក់ស្តុកមុខកូនកម្លោះមិនឲ្យឡើងទៅលើផ្ទះខាងស្រី ឬ កូនក្រមុំមិនឲ្យចូលទៅកាន់ខាងប្រុស ៗ បើម្តាយឪពុកនៃសាមីខ្លួនទាំងសងខាងអាណិតគ្នា កុំឲ្យឈរយូរពេក ខ្លាចនឿយហត់ ឬ ខ្មាសគេ គេយកតែអ្វីមួយមានស្រាទឹង សាច់ក្លែម ឬ ប្រាក់ជាដើមតាមសមគួរ ជូនអ្នកដោះត្រឡោកនោះ, បើអ្នកដោះគេសុខចិត្តព្រមបើកឲ្យទៅ ទើបចូលទៅបាន ៗ

ល្បែងនេះ ជាល្បែងមួយយ៉ាង នាំឲ្យអ្នកទស្សនាកើតសេចក្តីរីករាយ ហើយជាល្បែងដែលរាប់ចូលក្នុងការហាត់ប្រាណ នាំឲ្យដៃកើតសាច់ដុំ និងឲ្យដៃរហ័សរហួន ៗ

※

※ ※

www.elibraryofcambodia.org

# ១៣- ល្បែងសី

ល្បែងសី ជាល្បែងមួយយ៉ាងសម្រាប់មនុស្សប្រុសកម្លោះៗ ឬចំណាស់ៗ គេលេងនៅទីវាល នាពេលថ្ងៃរសៀលត្រជាក់ នៅវេលល្ងាចហើយ ឬនៅពេលបុណ្យទានផ្សេងៗ នាទីវត្តអារាមៗ

សីមាន ៣ យ៉ាង គឺ៖

ក - សីមីលោង

ខ - សីជីក

គ - សីពេន

សីទាំង ៣ យ៉ាង មានប្រដាប់សម្រាប់លេងនិងរបៀបលេងប្លែកពីគ្នា ដូចរៀបរាប់តទៅនេះ ៖

ក - សីមីលោង វត្ថុដែលគេយកមកធ្វើសីនេះ គឺគេយកបន្ទោះផ្តៅ ឬ ពោតមកចាក់ជាក្រឡាក្អែកក្រូច ឲ្យមានសណ្ឋានមូលប្រមាណប៉ុនត្រឡោកដូងតូច ហើយគេនាំគ្នាទាត់លេងៗ

សកម្មភាពនៃអ្នកលេងសីមីលោង ដូចក្នុងរូបភាពខាងមុខនេះ ៖

www.elibraryofcambodia.org



អ្នកលេងសីម៉ីលោងគេបបួលគ្នាចំនួន ៤ ឬ ៥ នាក់ ដែលគេស្ម័គ្រឲ្យមកឈរដេកង់ជារង្វង់មូលធំ ឬ តូច តាមចំនួនមនុស្សតិចច្រើន ។ ពេលលេងគេចែកជាគូ ៗ អ្នកណាគូនឹងអ្នកណា ត្រូវឈរទល់មុខអ្នកនោះ ៗ មុនដំបូង អ្នកលេងម្នាក់ដែលមានសីនៅនឹងដៃ ក៏តាំងផ្ដើមបោះសីទៅឲ្យគូរបស់ខ្លួន គូនោះក៏ទទួលទាត់ដោយខ្នងជើង, លុះទាត់ហើយ សីនោះក៏អណ្ដែតឡើងយ៉ាងខ្ពស់ ហើយធ្លាក់មកវិញ ពេលធ្លាក់នោះ ជួនក៏ចំអ្នកទាត់នោះវិញ ជួនក៏ចំអ្នកដទៃ ហើយអ្នកដែលសីធ្លាក់មកចំនោះក៏ទទួល

www.elibraryofcambodia.org

ចាត់ឡើងក្ដាម ៗ ចំណែកអ្នកឯទៀតៗ គេត្រៀមខ្លួនចាំ ដោយសង្ឃឹមប្រុងប្រយ័ត្នក្រែកជានិច្ច បម្រុងតែទឹងចាត់នៅពេលដែលសីធ្លាក់មកចំខ្លួន ៗ ម្នាក់ៗ ដែលសីធ្លាក់មកចំខ្លួន គេតែងស្ទុះទៅចាត់បញ្ជូនទៅឲ្យគូរបស់គេ ប៉ុន្តែជួនក៏បានទៅចំគូរបស់ខ្លួន ជួនក៏ធ្លាក់ទៅចំគូរបស់អ្នកដទៃ ម្លោះហើយ គេដណ្ដើមគ្នាចាត់តែរៀងខ្លួន ៗ

**១ – សីជក់** គេធ្វើដោយបន្ទោះផ្ដៅ ឬពោក ឲ្យមានសណ្ឋានដូចសីមលោងដែរ ប្លែកតែសីដក់គេធ្វើឲ្យមានទំហំនិងមានក្រឡាធំជាងសីមលោងបន្តិច ៗ សីដក់មានរបៀបលេងស្រដៀងនឹងសីមលោងដែរ ប្លែកតែសីម-លោងគេចាត់ដោយខ្នងជើង, ឯសីដក់គេគះដោយកែងដៃ ដោយក្បាលជង្គង់ ដោយស្មា និងដោយក្បាល ៗ



សកម្មភាពរបស់អ្នកលេងសីដក់ ដូចរូបភាពនេះ :

www.elibraryofcambodia.org

គ–សីពែង គេធ្វើដោយស្លាបសត្វ និងស្បែក ឬ ស្រកាត្រី គឺដាក់ស្បែក ឬស្រកាត្រីត្រួតគ្នា ៣-៤ ជាន់ ចៀរជាសណ្ឋានមូល ចោះចំកណ្ដាល ជាប្រហោង ហើយយកស្លាបសត្វ ៤-៥ ដែលខ្លីៗល្មម មកផ្គុំឲ្យស្មើ រួចស៊កគល់ស្លាបនោះក្នុងរន្ធស្បែក ឬស្រកាត្រីនោះឲ្យ ចេញមកបន្តិច ហើយបត់ទៅខាងៗ ចងដោយខ្សែលួសស្ពាន ភ្ជាប់ទៅនឹង ស្បែក ឬស្រកាត្រីនោះ ការពារមិនឲ្យរបូត រួចគេយកទៅទាត់ ៗ

សកម្មភាពរបស់អ្នកលេងសីពែង ដូចក្នុងរូបភាពនេះ :



www.elibraryofcambodia.org

**របៀបលេងសីពែន** គេបបួលគ្នាឲ្យបានចំនួនតាំងពី ២ នាក់ឡើងទៅ មកឈរជុំគ្នាជារង្វង់មូល ទល់មុខគ្នាជាគូ ៗ គឺអ្នកណាគូនឹងអ្នកណា ត្រូវឈរទល់មុខគ្នានឹងអ្នកនោះ ។ កាលបើឈរស្រួលបួលហើយ ម្នាក់ដែលកាន់សីនៅដៃគឺបោះសីទៅឲ្យម្នាក់ទៀត ដែលជាគូរបស់គេ គូនោះក៏ទទួលទាត់ដោយបាតជើង គឺគេលើកជើងឡើងហើយរលាស់បត់ត្រង់កជើងឲ្យបាតជើងខ្វែរឡើងលើ ដូចគេអង្គុយពែនទើបគេហៅថា "សីពែន" ។ ពេលទាត់គេទាត់តម្រង់ឲ្យចំសី ៗ ក៏អណ្តែតឡើង ហើយធ្លាក់ចុះមកវិញ បើធ្លាក់មកចំអ្នកណា អ្នកនោះគេទាត់បន្តឡើងទៀត, បើធ្លាក់មកចំអ្នកទាត់ដដែលវិញ អ្នកនោះក៏ទទួលទាត់វិញដែរ ។ បើសីធ្លាក់មកចំអ្នកណាហើយអ្នកនោះទទួលទាត់មិនត្រូវ ឬក៏សីនោះធ្លាក់ឆ្ងាយអំពីអ្នកលេងទាំងអស់គ្នា នាំឲ្យអ្នកលេងរត់ទៅទទួលទាត់មិនទាន់ សីក៏ធ្លាក់ដល់ដី បើធ្លាក់ក្បែរកន្លែងអ្នកណាជាងគេ អ្នកនោះគេរើសបោះទៅឲ្យគូរបស់គេ ដើម្បីឲ្យទាត់តទៅទៀត ។ ពេលដែលសីធ្លាក់មកម្តង ៗ ទាំងអស់គ្នាតែងតែសំឡឹងមើលទៅសីគ្រប់ ៗ គ្នា ក្រែងធ្លាក់មកចំខ្លួន ជួនក៏អ្នកទាំង ២ នាក់នឹកត្រូវគ្នា គឺនាក់ម្នាក់នឹកថា សីធ្លាក់មកចំខ្លួន ម្នាក់ទៀតក៏ថា ចំខ្លួនដែរ នាំឲ្យស្ទុះទៅទាត់ដណ្តើមគ្នាក៏មាន ។

www.elibraryofcambodia.org

ម្នាក់ៗ ដែលសីធ្លាក់មកចំហើយ តែងតែមានចិត្តទឹកថា នឹងទាត់បង្វើរទៅឲ្យគូរបស់ខ្លួន ៗ តែជួនកាលក៏បានសម្រេច ជួនកាលក៏មិនបានសម្រេចដែរ ដោយសីនោះមិនទៅចំដូចបំណង ៗ

សីពេននេះ គេទាត់ ឬ គះ បានតែដោយបាតជើង, ក្នុកគោល, កែងជើង, កែងដៃ, ក្បាលជង្គង់, ក្បាល, ស្មា ប្រហែលសីដក់ដែរ តែគេហាមផ្តាច់មិនឲ្យទាត់ដោយខ្នងជើង ឬទះដោយបាតដៃឡើយ ៗ

ល្បែងសីទាំង ៣ មុខនេះ បើអ្នកលេងសុទ្ធតែប៉ិនប្រសប់ ក្នុងពេលទាត់មួយលើក ៗ សីមិនសូវធ្លាក់ដល់ដីទេ យូរ ៗ ទើបមានធ្លាក់ដល់ដីម្តង ៗ

ល្បែងសី ជាកីឡាដ៏ប្រសើរមួយរបស់ខ្មែរ តាំងពីអតីតកាល រហូតមកដល់បច្ចុប្បន្នកាលនេះ ក៏នៅតែមានតម្លៃនៅឡើយ ហើយជាកីឡាហាត់ប្រាណមួយយ៉ាង ខាងកាយសម្បទា ប្រហែលនឹងកីឡាបាល់ទាត់ដែរ ៗ

※

※ ※

www.elibraryofcambodia.org

# ១៤- ល្បែងទាញព្រ័ត្រ

**ល្បែងទាញព្រ័ត្រ** ជាល្បែងលេងកំសាន្តសប្បាយរបស់យុវជនខ្មែរទាំងប្រុស ទាំងស្ត្រី កម្លោះ ក្រមុំ ។ ល្បែងនេះ គេលេងដោយប្រើកម្លាំងកាយជាមូលហេតុ ហើយគេលេងតែនៅរដូវបុណ្យចូលឆ្នាំខ្មែរ គឺខែចេត្រ-ពិសាខប៉ុណ្ណោះ ។ គេច្រើននិយមលេងក្នុងវត្តអារាម ក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ព្រោះវត្តមានទីកន្លែងធំទូលាយ ងាយដល់ការលេងល្បែងនេះ, តែអាចលេងនៅតាមភូមិក៏បាន បើប្រសិនជាភូមិនោះមានមនុស្សនៅផ្តុំគ្នាច្រើន ហើយមានទីកន្លែងល្មមលេងកើត ។ ល្បែងនេះគេច្រើនលេងនៅពេលថ្ងៃ តែបើប្រសិនជាមានចង្កៀងយ៉ាងភ្លឺ ឬពន្លឺព្រះចន្ទភ្លឺថ្លាល្អ គេអាចលេងនៅពេលយប់ក៏បាន ។

**សមាសភាពនៃអ្នកលេង** ល្បែងនេះ គេចែកមនុស្សអ្នកលេងជា ២ ក្រុម ម្ខាង ១ យ៉ាងតិចត្រឹម ៥ នាក់ ឬ ១០ នាក់ឡើងទៅតាមដែលគេរកគ្នាបានប៉ុន្មាន ក៏លេងប៉ុណ្ណោះ តែតាមទម្លាប់អ្នកស្រុក បើមានមនុស្សស្រីចូលលេងផង គេឲ្យស្រី ១ នៅម្ខាង ប្រុស ១ នៅម្ខាង

www.elibraryofcambodia.org

ហើយគេយល់ថា គេចស្រីតែងមានកម្លាំងខ្សោយជាងប្រុស គេតែងដាក់ខាងស្រីឲ្យមានចំនួនច្រើនលើសប្រុស យ៉ាងតិចត្រឹម២ នាក់ជាដរាប គឺបើខាងប្រុស ៨ នាក់ គេដាក់ខាងស្រី ១០ នាក់ ។

**គ្រឿងប្រដាប់សម្រាប់លេង** គេយកខ្សែព្រ័ត្រធ្វើពីស្បែកគោ ស្បែកក្របីធ្វើជាព្រ័ត្រ ឬគេយកពួរធ្វើពីផក់ដូងជាព្រ័ត្រ សម្រាប់ទាញ ប្រវែងយ៉ាងខ្លីពី ២០ ហត្ថឡើងទៅ ទំហំប៉ុនកដៃក្មេង ហើយទីងយកសម្ពោរ ឬគងម៉ង់ ឬកំគាំង ១ សម្រាប់ទះ ឬសម្រាប់វាយ នៅពេលដែលទាញដំបូង ។

សកម្មភាពនៃអ្នកលេង ដូចក្នុងរូបភាពនេះ :



**របៀបលេង** មុនដំបូង គេរើសក្មេងប្រុសម្នាក់ ស្រីម្នាក់ មាន

www.elibraryofcambodia.org

មាឌធំមា ស្វាគាំង កម្លាំងច្រើន ឲ្យជាអ្នកឈរកាន់ចុងព្រ័ត្រ គឺប្រុសកាន់ចុងម្ខាង ស្រីកាន់ចុងម្ខាង ហើយឲ្យប្រុសម្នាក់ស្រីម្នាក់ទៀត មានមាឌធំ មានកម្លាំង ឈរកណ្ដាលព្រ័ត្រ ត្រង់កន្លែងដែលពួកទាំង ២ ឈរ សម្រាប់នាំពួកខ្លួនឲ្យខំទាញតែរៀងខ្លួន ឯមនុស្សមាឌតូចៗស្គមៗ កម្លាំងខ្សោយៗ គេឲ្យឈរកណ្ដាលគេ ។ លុះរៀបចំរួចហើយ, គេឲ្យមនុស្សប្រុសម្នាក់កាន់សម្ពោរ ឬគងម៉ង់ ឬក្រគាំង ឈរត្រង់កណ្ដាលទី ជិតអ្នកទាំងពីរដែលកាន់ខ្សែឈរប្រទល់មុខគ្នា នោះ ផ្ដើមស្រែកឡើងថា យក្សអរ(១)!! ពួយ៉ាងខ្លាំងៗ ផ្ទើសំឡេងវែងៗ លោក់លែក យ៉ាងគ្រលួចៗ ឯអ្នកប្រុងទាញព្រ័ត្រទាំងប៉ុន្មានជួយស្រែកទទួលឡើង ព្រមគ្នាថា ហើរ៉ុ ១ ៣ ដង ទើបនាំគ្នាទាញប្រុងយកជ័យជំនះតែរៀងខ្លួន ។ ក្នុងពេលពួកអ្នកទាញព្រ័ត្រ កំពុងតែខំប្រឹងទាញ អ្នកកាន់សម្ពោរ ឬគងម៉ង់ ឬក្រគាំង គេបេះតែបញ្ឈឹតសម្ពោរ ឬគងម៉ង់ ឬក្រគាំងឡើយៗ ឮសូរគាក់ទីងៗ ឬ ម៉ូងៗម៉ុងៗ ជាដកប ទាល់តែឃើញចាញ់ ឃើញឈ្នះម្ខាងៗ ទើបឈប់បញ្ឈឹត ។

ពេលលេងម្ដងៗ អស់ថេរវេលាពី ៥–៦ នាទី ដល់ ១០ នាទី

---

២– ពាក្យ យក្សអរ នេះ អ្នកស្រុកតែងហៅថា ជាកក្អម្ម គេទុកជាពាក្យផ្ដើម សម្រាប់ប្រើស្រែកក្នុងពិធីផ្សេងៗ មានការទាញព្រ័ត្រ ឬ ការសែងទូកចុះបាក់បង្គង ឬ ក៏លើកដាក់លើបង្គង ជាដើម ។

www.elibraryofcambodia.org

ឡើងទៅ ទើបឃើញឈ្នះ ឃើញចាញ់ម្ខាង ៗ ។

កាលដឹងថាខាងណាឈ្នះខាងណាចាញ់ហើយ គេចាប់ផ្ដើមលេងសាជាថ្មីទៅទៀត ដកបដល់ហត់តែរៀងខ្លួន ទើបឈប់ ។

ល្បែងនេះ ចាត់ទុកជាការហាត់កម្លាំង ហាត់ប្រាណ ឲ្យរាងកាយមានកម្លាំង មានសុខភាពល្អ ។

※

※ ※

www.elibraryofcambodia.org

# ១៥_ ល្បែងកូនគោល

ល្បែងកូនគោល អ្នកស្រុកខ្លះគេហៅ " ល្បែងប្រដំ " ជាល្បែងរបស់មនុស្សកម្លោះ ក្រមុំ ឬ ក្មេងជំទង់ តែងលេងនៅពេលទំនេរ នារដូវប្រាំង ឬ រដូវចូលឆ្នាំ ។

ប្រដាប់លេង មាន ២ មុខ គឺ ដំបង ឬ ទំពក់សម្រាប់វាយ ឬ ប្រដំមួយមុខ កូនគោល ឬ កូនប្រដំ ១ មុខ ។ ដំបង ឬ ទំពក់ គេធ្វើពីគល់ឫស្សីព្រៃ ឬ គល់ពីងពង់ ទំហំប៉ុនកដៃក្មេង មានដងស្រលូតគល់ក្រងក់ ។ កូនគោល ឬ កូនប្រដំ គេធ្វើពីឈើសាច់ស្អាត ៗ ស្រាល ៗ មានឈើល្មួស ឬ គរជាដើម ។

កូនគោល ឬកូនប្រដំ មាន ២ បែប: ១ បែបសម្រាប់លេងក្នុងវេលាថ្ងៃ ១ បែបទៀតសម្រាប់លេងក្នុងវេលាយប់ ។ បើលេងវេលាថ្ងៃ គេយកឈើល្មួស ឬគរមកកាត់ជាកង់ ១ ហើយលុបជ្រុងធ្វើឲ្យមូល ហាលថ្ងៃឲ្យស្ងួត ហើយយកទៅវាយលេង ។ បើលេងវេលាយប់ គេយកឈើល្មួស ឬគរដែលកាត់ជាកង់ ១ នោះ ដុតភ្លើងឲ្យឆេះចេញរងើក ហើយយកទៅវាយលេង ឲ្យមើលទៅឃើញភ្លឺក្រហមឆ្អៅ ធ្លាចុះធ្លា

www.elibraryofcambodia.org

ឡើង តាមរយៈដែលរាយទៅមក ។ កូនគោលភ្លើង ស្រុកខ្លះគេលេងជាការកំសាន្ត ស្រុកខ្លះគេលេងជាការបណ្តេញខ្មោចបិសាច ក្នុងពេលស្រុកកើតជម្ងឺ ។

ទីកន្លែងលេង គេច្រើនយកទីដីវាលស្រែ ឬចម្ការ ដែលមានទំហំធំទូលាយ ស្អាតល្អ ឬបើមានផ្ទៃថ្នល់ធំវែងទូលាយជាទីស្អាត ជួនកាលគេក៏យកជាទីលេងខ្លះដែរ ។

ល្បែងនេះ គេចែកមនុស្សអ្នកលេងជា ២ ពួក មានចំនួនស្មើគ្នា យ៉ាងតិចពី ២ ឬ ៤ នាក់ឡើងទៅ បើអ្នកលេងមានប្រុសផង ស្រីផង ប្រុសលេងជាមួយប្រុសក៏បាន, ស្រីលេងជាមួយស្រីក៏បាន ស្រីម្នាក់ប្រុសម្នាក់លេងជាមួយគ្នាក៏បាន ។ ពេលលេង គេគូសដីចំកណ្តាលទីជាស្នាម ហើយគេយកភ្លឺស្រែ ឬចម្ការ ឬក៏ជាតម្រុយម្ខាង ៗ ខាងឆ្វេងដៃរបស់គេធ្វើជាគ្រឿងចំណាំ បើអ្នកលេងសុទ្ធតែប្រុស គេឲ្យប្រុស ២ នាក់ ឈរចំស្នាមនោះ បើអ្នកលេងសុទ្ធតែស្រី គេឲ្យស្រី ២ នាក់ឈរចំស្នាមនោះ, បើអ្នកលេងស្រីម្នាក់ប្រុសម្នាក់ គេឲ្យប្រុសម្នាក់ស្រីម្នាក់ឈរចំស្នាមនោះ បែរមុខរកគ្នា ហើយបណ្តាអ្នកទាំង ២ នោះ ម្នាក់កាន់កូនគោល ឬកូនប្រផំមកដាក់ត្រង់កណ្តាលស្នាមគូសនោះ ទើបអ្នកទាំង ២ នោះគេកាន់ចុងដំបង ឬទំពក់ ១ ម្នាក់ លើកគលឡើងប្រ-ទាស់គ្នាហៅថា "កែ" គឺវាយលៗផ្លាស់ប្តូរគ្នា ពីស្តាំទៅឆ្វេង ពីឆ្វេង

www.elibraryofcambodia.org

ទៅស្ដាំ ចំនួន ៣ ដង ហើយអ្នកទាំង ២ នាក់នោះ ស្ទុះវៃលួចល្បក់គ្នាដាយកូនគោលឬកូនប្រដាំនោះ ពីស្ដាំទៅឆ្វេងរបស់ខ្លួន ដើម្បីឲ្យកូនគោល ឬ កូនប្រដាំនោះតែទៅកាន់ទីខាងឆ្វេងជានិច្ច ដែលគេទុកជាទីរបស់គេរៀងខ្លួន ៗ

សកម្មភាពរបស់អ្នកលេង ដូចក្នុងរូបភាពនេះ :



ល្បែងនេះមានប្រណាមតឹងណាស់ គឺពេលកំពុងប្រយុទ្ធដណ្ដើមកូនគោល ឬ កូនប្រដំគ្នា គេតមមិនឲ្យអ្នកលេងទាំងសងខាងយកដៃចាប់កូនគោលឬកូនប្រដំនោះបោះទៅទីរបស់ខ្លួនទេ គ្រាន់តែទាត់នឹងជើងបាន បើខាងណាម្នាក់យកដៃចាប់កូនគោល ឬកូនប្រដំ គេទុកការនោះជាអសារបង់ ត្រូវយកកូនគោល ឬកូនប្រដំទៅកែសាជាថ្មី ៗ មួយទៀត គេតម

www.elibraryofcambodia.org

មិនឲ្យអ្នកវាយទាំងសងខាងឈរ ឬគេទៅដណ្ដើមយកកូនទាល់ទីទេ ត្រណមខាងក្រោយនេះ អ្នកលេងគេប្រយ័ត្នណាស់ ព្រោះដើរខុសត្រណមនេះរមែងមានគ្រោះថ្នាក់ ។

ល្បែងនេះ គេយកចាញ់ឈ្នះគ្នា ត្រង់ការដែលគូប្រយុទ្ធដណ្ដើមវាយកូនគោលឬកូនប្រដំឲ្យចូលទៅផលចុងទីរបស់ខ្លួនបាន ។ បើខាងណាគេវាយកូនគោល ឬកូនប្រដំឲ្យចូលទីខាងគេបាន ឈ្មោះថាគេមានជ័យជំនះ ហើយគេលេងសារឡើងជាថ្មី គ្រាន់តែដល់ពេលឈប់លេង ទើបគេយកចំនួនលើកដែលឈ្នះចាញ់នោះមកគិតមើល ឲ្យដឹងថាខាងណាឈ្នះប៉ុន្មានលើក ខាងណាចាញ់ប៉ុន្មានលើក គឺឈ្នះម៉ុន្មានទល់នឹងចាញ់ប៉ុន្មាន តែគ្រាន់តែជាកិត្តិយស ឥតមានស៊ីសងជាវត្ថុអ្វីទេ ។

តាមសេចក្ដីឲ្យការណ៍ខ្លះថា ល្បែងនេះនៅស្រុកខ្លះ គេយកស្រកីដូងមកឆ្លលចង់ឲ្យមូលធ្វើជាកូនគោល ហើយគេទាត់ដោយជើង ។ របៀបយកចាញ់យកឈ្នះ ប្រហែលគ្នានឹងកូនគោលឈើ ដែលវាយដោយដំបងនោះដែរ ។

ល្បែងនេះ ជាល្បែងរបស់ខ្មែរសម័យបុរាណ ដែលកប់ចូលក្នុងពួកកីឡា ចាស់ទាត់ ចាស់បោះ ចាស់ទះ កូនឃ្លី ក្នុងសម័យបច្ចុប្បន្ននេះបាន ។

www.elibraryofcambodia.org

# ១៦- ល្បែងរាវបង្កង

ល្បែងរាវបង្កង(១) ជាល្បែងមួយយ៉ាង សម្រាប់លេងកំសាន្តសប្បាយនៃពួកកុមារកុមារីតូចៗ ឬធំៗ ។ គេលេងនៅពេលរាត្រីខែភ្លឺក៏បាន ពេលថ្ងៃក៏បាន ចំនួនអ្នកលេងមិនកំណត់ ។

សកម្មភាពរបស់អ្នកលេង ដូចក្នុងរូបភាពនេះ ៖



មុននឹងលេង គេបបួលពួកកុមារកុមារីឲ្យបានច្រើនគ្នា ។ គេយកក្រមាឬកន្សែងចងខ្ទប់ភ្នែកកុមារ ២ នាក់ឲ្យជិត ហើយគេលែងកុមារទាំង ២ នាក់នេះឲ្យដើររកចាប់គ្នា ។ បណ្ដាអ្នកទាំង ២ នេះ គេឲ្យម្នាក់កាន់បំពង់ឬស្សី ឬត្រឡោកដូងក៏បាន ដើរគោះត្រង់នេះ ១ ប៉ុក ត្រង់

១- ស្រុកខ្លះហៅថា ល្បែងអកខ្វាក់អកខ្វិន របៀបលេងប្រហែលគ្នា ។

www.elibraryofcambodia.org

នោះ ១ ប៉ុក ពេលដែលគោះហើយ អ្នកគោះនោះត្រូវគេចខ្លួនឲ្យរហ័ស ដោយកុំឲ្យត្រូវស្នូរជើង ។ ចំណែកម្នាក់ទៀត ជាអ្នកការគេចាប់អ្នកគោះ បំពង់ឬស្សី ឬត្រឡោកដូងនោះ កាលណាត្រូវស្នូរសំឡេងគេគោះត្រង់ណា អ្នកការកំស្ទុះទៅស្រវាឱបដោយស្មានទៅកន្លែងនោះ ឬកន្លែងក្បែរៗនោះ ស្រេចតែគិតល្បិចរបស់ខ្លួនយ៉ាងណា ឲ្យតែចាប់អ្នកគោះបាន ។ បើអ្នកការគេបុនស្ដាប់ស្នូរជើងដើរ គេកំស្ទុះទៅឱបស្មានៗ ត្រង់កន្លែងស្នូរជើងនោះ ជួនកំការចាប់បាន ជួនកំមិនបាន ។ បើកាលណាអ្នកការគេចាប់មិនបាន គេទុកអ្នកគោះត្រឡោកនោះជាឈ្នះ បើអ្នកការចាប់បាន គេឲ្យអ្នកការធ្វើជាអ្នកគោះត្រឡោកវិញម្ដង គេលេងតែរបៀបនេះរហូតដល់ពេលឈប់លេង ឯអ្នកណាជាអ្នកគោះត្រឡោកមុន ឬជាអ្នកការគេមុននោះ ពុំកំណត់ទេ ស្រេចលើការព្រមព្រៀងគ្នា ។

ល្បែងនេះ ជាការហាត់ត្រចៀកឲ្យស្ទាត់ក្នុងការស្ដាប់សម្លេង និងឲ្យមានស្មារតីវៃប៉ិនរហ័សដៃ-ជើង ។

※

※ ※

www.elibraryofcambodia.org

# ១៧- ល្បែងបោះប្រមាត់

**ល្បែងបោះប្រមាត់** ជាល្បែងដែលមានតែនៅភូមិកំពង់ភ្លុក, ភូមិកំពង់ឃ្លាំង ស្រុកសូទ្រនិគម និង ស្រុកជីក្រែង ខេត្តសៀមរាប ជាភូមិនៅមាត់ទន្លេសាប ។ អ្នកស្រុកទាំងនេះគេតែងលេងល្បែងនេះ ប្លែកពីស្រុកឯទៀត ។

ល្បែងនេះ គេលេងតែក្នុងរដូវវស្សា តាំងពីពេលដាក់បិណ្ឌទៅ ទល់នឹងថ្ងៃចេញវស្សា គឺពីថ្ងៃ ១ រោច ខែភទ្របទ ទៅទល់នឹងថ្ងៃ ១៥ កើត ខែកត្តិក រៀងរាល់ឆ្នាំ ។

**របៀបលេង** មានទូកពីរ, ១ សម្រាប់ដេញ សុទ្ធតែប្រុស, ១ សម្រាប់រត់សុទ្ធតែស្រី ទំហំនឹងចំណុះទូកស្មើគ្នា ហើយចំណុះមានកំរិតត្រឹមពី ៤ នាក់ ទៅ ១០ នាក់យ៉ាងច្រើន ។ បើមានអ្នកលេងច្រើន គេផ្គូទូកជាគូៗ ទូកប្រុស ១ ទូកស្រី ១ ជាមួយគូ ។

សកម្មភាពរបស់អ្នកលេង ដូចក្នុងរូបភា[illegible]ានេះ :

www.elibraryofcambodia.org



គេលេងល្បែងនេះ ក្នុងទីដែលមានទឹកពក់ៗ ជម្រៅត្រឹមក ឬលិចក្បាល ។ ពេលផ្ដើមលេង អ្នកលេងទាំងពីរពួក គេចុះទូកពេញ ៗ ចំណុះតែរៀងខ្លួន ហើយទូកខាងប្រុសធ្វើជាអុំលេង ៗ ទៅរកទូកខាងស្រីណាដែលជាគូទន់ទូកខ្លួន លុះខាងប្រុសអុំលេង ៗ ទៅជិតទូកខាងស្រី ប្រុស ៗ ស្រែកសួរថា "ហោះប្រមាត់?" ស្រីៗ ជួនកាលឆ្លើយថា "ហោះក៏ហោះ" ជួនកាលឆ្លើយថា "ទេ" ជួនកាលឥតឆ្លើយតប ៗ ឯខាងប្រុសទោះបានឮពាក្យថា ព្រមក្ដី មិនព្រមក្ដី ឬស្ងៀមក្ដី ក៏ស្រែកព្រមគ្នាថា "ដេញៗ" ឮតែប៉ុណ្ណោះ ខាងស្រីក៏អុំទូករត់ ខាងប្រុសក៏ប្រឹងអុំតាម ៗ ការដេញតាមនោះ ជួនកាលទាន់ ជួនកាលទេ ស្រេចលើកម្លាំងរៀងខ្លួន បើខាងប្រុសដេញទាន់ ក៏គេលោតទៅគោងទាញទូកខាងស្រីឲ្យលិច ហែលព្រាតព្រោង ៗ ពេលនោះខាងស្រីៗ ឥតមានប្រកាន់ខ្លួនឡើយ គេចេះតែប្រឡែងប្រឡូកគ្នាក្នុងទឹក ប្រុសៗ

www.elibraryofcambodia.org

ដេញញៀបស្រី ៗ ត្រាតែរស់ចិត្តរស់ថ្មើម ហក់រៀងខ្លួន ទើបគេនាំគ្នាស្តារទុកឡើង ហើយគេនាំគ្នាអុំលេងតទៅទៀតសារជាថ្មី កាលដេញទាន់គ្នាបាន គេញៀបគ្នាជាថ្មីទៀត ៗ បើលេងពេលព្រឹកត្រាតែដល់ពេលថ្ងាយ បើលេងពេលយប់ ត្រាតែពាក់កណ្ដាលអធ្រាត្រ ទើបខាងប្រុសគេបើកឲ្យខាងស្រីទៅផ្ទះរៀងខ្លួន ៗ

ល្បែងនេះ ជាទំនៀមរបស់អ្នកស្រុក ដូចមានឈ្មោះខាងលើ គេលេងដោយស្មោះត្រង់ ឥតមានប្រកាន់ថាខុសត្រូវអ្វីឡើយ គិតតែនាំគ្នារីករាយសប្បាយជាកំសាន្តមួយយ៉ាងប៉ុណ្ណោះ ៗ

ល្បែងនេះ រាប់ចូលក្នុងការហាត់ប្រាណ ហាត់កម្លាំងឲ្យរាងកាយឡើងសាច់ដុំមានសុខភាពល្អ ប្រហាក់ប្រហែលគ្នានឹងកីឡាហែលទឹកសព្វថ្ងៃនេះដែរ ៗ

www.elibraryofcambodia.org

# ១៨- ល្បែងបាយខុំ

ល្បែងបាយខុំ ជាល្បែងមួយយ៉ាងដែលអ្នកស្រុកគ្រប់ជនបទក្នុងប្រទេសកម្ពុជាទាំងមូល គេតែងលេងកំសាន្តនៅពេលទំនេរម្តងម្កាល ។

របៀបលេង និងសម្ភារៈ សម្រាប់លេង គេជីកដីជារណ្តៅតូចៗ ឬគេយកចានតូច ៗ ឬគេចោះក្តារ ១ បន្ទះធំឲ្យមានជម្រៅចំនួន ៣ ឬ ៤ សង្ទីម៉ែត្រ ធ្វើជារន្ធ ១០ ដាក់គ្រាប់សម្រាប់លេង ។ បណ្តារន្ធទាំងនោះ រន្ធធ្វើពីឈើ ឬចានស្រួលលេងជាងគេ ព្រោះលេងហើយគេអាចយក-ទៅប្រើទីណាក៏បានឬគេទុកលេងថ្ងៃក្រោយទៀតក៏បាន ។ រន្ធទាំងនេះ គេធ្វើជា ២ ជួរ ១ ជួរ ៥ ៗ ឲ្យមានសណ្ឋានដូចពងក្រពើ ។ បណ្តារន្ធទាំង ២ ជួរនោះ ក្នុងមួយជួរ មានរន្ធ ១ ខាងដើមជាមេ ហៅថារន្ធក្បាលដំរឿង ។ លុះធ្វើហើយគេយកវត្ថុដែលមានដុំតូចៗ ដូចជាគ្រាប់បម្បក់ គ្រាប់អម្ពិល សំបកខ្ចៅ ឬផ្លែកន្ទួតស្រុក កន្ទួតព្រៃជាដើម, ដែលអ្នកផងនិយមយកមកលេងជាងគេនោះ ច្រើនតែគ្រាប់អម្ពិល(១) ឬក្រួសតូច ៗ ព្រោះជារបស់ស្ទួតស្រួលលេង ៗ ក្នុងរន្ធទាំង ១០ នោះ

---

១- តាមទម្លាប់ស្រុកខ្លះ សន្មតហៅគ្រាប់នេះថា ជៀប ។

www.elibraryofcambodia.org

រន្ធក្បាលដីមៀនត្រូវដាក់គ្រាប់ ៥ ក្រៅពីនោះដាក់តែ ៤ គ្រាប់ៗ ស្មើគ្នា រួមទាំងអស់ត្រូវជា ៥២ គ្រាប់ ។

ពេលលេង អ្នកលេងតាំង ២ នាក់ អង្គុយទល់មុខគ្នា ម្ខាងម្នាក់ រន្ធបាយខុំនៅជាកណ្ដាល ។ ឯរន្ធក្បាលដីមៀន ត្រូវនៅខាងស្ដាំដៃរៀងខ្លួន(១) ។

សកម្មភាពរបស់អ្នកលេង ដូចរូបភាពនេះ ៖



កាលបើដាក់គ្រាប់ហើយ គេឲ្យម្នាក់ចាប់ផ្ដើមដើរគ្រាប់មុន(២) អ្នកដើរ គេចាប់យកគ្រាប់ដោយដៃស្ដាំ អំពីរន្ធណាមួយខាងស្រុករបស់ខ្លួន ដាក់ ១ គ្រាប់ទៅក្នុងរន្ធ ឬចានខាងស្ដាំ ឬខាងឆ្វេង បន្ទាប់ពីរន្ធ ឬចានដែលខ្លួនបាន ចាប់ពីដំបូងនោះ ៗ ដាក់គ្រាប់ ១ ទៅក្នុងរន្ធ ឬចាននោះ ហើយដាក់គ្រាប់ ១

១) - តាមនិយមស្រុកខ្លះ ស្រេចនៅលើសន្មតគ្នាជាមុន ថាយកខាងឆ្វេង ឬខាងស្ដាំ ។

២) - ដំបូងកាលគេដើរញែកគ្រាប់ គឺមុននឹងដើរទៅស្ដាំ ត្រូវដាក់មួយគ្រាប់មករន្ធខាងឆ្វេងសិន។

www.elibraryofcambodia.org

ទៀតទៅក្នុងរន្ធបួនបន្ទាប់ ដែលនៅជិតគ្នានោះតទៅទៀត ដាក់ ១ រន្ធ ១ គ្រាប់ ៗ ទាល់តែអស់គ្រាប់ ដែលកាន់នៅដៃ ។ កាលបើអស់គ្រាប់នៅក្នុងដៃត្រង់រន្ធណា ទើបគេចាប់យកគ្រាប់ពីរន្ធបន្ទាប់នោះពាយតទៅទៀត បើអស់គ្រាប់ត្រង់រន្ធណាមួយហើយ ឃើញរន្ធ ១ បន្ទាប់នោះទទេ គេលូកកិះរន្ធនោះ ហើយគេចាប់យកគ្រាប់ក្នុងរន្ធបន្ទាប់នោះលើកឡើងយកមកទុកនៅមុខគេ ហៅថាស៊ី តែបើស៊ីបរន្ធណាដែលមានរន្ធទទេតទៅទៀត គេអាចកិះស៊ីបន្តទៅទៀត ទោះជា ២ ដំណ ៣ ដំណក៏ដោយ ។ បើដើរពាយគ្រាប់ទៅអស់ត្រង់រន្ធណា ហើយរន្ធបន្ទាប់នោះគ្មានគ្រាប់ផលទៅ ២ រន្ធ នោះគេហៅថា ឃ្លាង ឥតបានស៊ីទេ បើដើរពាយគ្រាប់ទៅ អស់ត្រង់រន្ធណា ហើយរន្ធបន្ទាប់នោះ ឥតមានគ្រាប់ រន្ធបន្ទាប់មកទៀតមានគ្រាប់តែ ១ នោះ គេហៅថា ស៊ីម៉ី គឺស៊ីបានតែមួយម៉ង ៗ

របៀបចាញ់ឈ្នះនោះ គឺអ្នកម្ខាងស៊ីអស់អ្នកម្ខាងគ្មានគ្រាប់ដាក់រន្ធខ្លួនពុំបាន កាលបើដូច្នេះ អ្នកឈ្នះយកគ្រាប់ ២១ ដាក់ទៅក្នុងរន្ធ ១ ម្តង ៗ ឲ្យអ្នកចាញ់ផ្លុំបញ្ចេញពីរន្ធ ឬដាក់លើមាត់រន្ធឲ្យអ្នកចាញ់ផ្លុំបញ្ចូល ឲ្យទាល់តែអស់គ្រាប់ទាំង ២១ នោះ បើផ្លុំមិនចេញ ឬមិនចូលអស់ទេ គេជោះក្បាលជង្គង់អ្នកចាញ់ ២១ ដៃ ទើបគេចាប់លេងតទៅទៀត ។

www.elibraryofcambodia.org

ល្បែងថ្លាយខ្ញុំ ជាល្បែងមួយយ៉ាងកាចកាប់ចូលក្នុងការហាត់គំនិត ខាងគិតលេខ ទឹងគល់ល្បិចវាងវៃក្នុងស្មារតី ចំពោះរបៀបលៃលករក ចំណេញ ឲ្យឃើញទៅពេលខាងមុខវែងឆ្ងាយជាមុន ។

※

※ ※

www.elibraryofcambodia.org

# ១៩- ល្បែងលាក់កូនកាស

**ល្បែងលាក់កូនកាស** ជាល្បែងមួយយ៉ាងសម្រាប់ក្មេងធំៗ លេងកំសាន្តសប្បាយ ។ ល្បែងនេះ គេលេងបានតែនៅក្នុងទឹកអូរ ឬទន្លេដែលមានជម្រៅត្រឹមចង្កេះ ឬត្រឹមដើមទ្រូងក្មេងៗ អ្នកត្រូវការលេងនោះ ។ ។

**របៀបលេង** ក្មេងៗបបួលគ្នាឲ្យបាន ៤-៥ នាក់ឡើងទៅ គេចុះទៅក្នុងទឹកជម្រៅដូចពោលខាងលើ ហើយយកកំណាត់ឈើ ឬដើមស្នោរខ្លីៗ ដែលជាវត្ថុស្រាលៗអណ្តែតទឹក ធ្វើជាខ្លាប់ជាក់បណ្តែតលើខ្នងទឹក បង្ហាញអ្នកលេងទាំងអស់គ្នា ឲ្យឃើញច្បាស់ទីងក្នែកថានេះជា " កូនកាស " កុំឲ្យច្រឡំនឹងកំណាត់ឈើឯទៀត, ហើយអ្នកលេងទាំងអស់គ្នា គេនាំគ្នារើសកំណាត់ឈើផ្សេងៗ ដែលមាននៅក្នុងទឹកត្រង់កន្លែងលេងនោះចេញអស់ ដើម្បីកុំឲ្យច្រឡំ នឹងកូនកាសរបស់ខ្លួន ហើយគេនាំគ្នាឈរជុំគង់ជាវង់ក្នុងទឹក ដាក់ខ្លាប់ជាកូនកាស់នៅចំកណ្តាលវង់ ។

សកម្មភាពនៃអ្នកលេង ដូចក្នុងរូបភាពខាងមុខនេះ :

www.elibraryofcambodia.org



លុះរៀបស្រួលបួលហើយ គេនាំគ្នាក្រោកទឹកពន្លិច ម្ជុបទន្ទ្រាត់ក្បួនកាសាបញ្ញ ហើយឈប់បង្អង់បន្តិច ទើបនាំគ្នាគន់រកមើលខ្នាច់ ដែលអណ្ដែតឡើង ហើយស្ទាត់ឆ្ងាយពីខ្លួន បើអ្នកណាគេឃើញមុនគេ(១) ហើយចាប់យកខ្នាច់នោះបាន អ្នកនោះត្រូវដេញញៀចស៊ីកត្រចៀក គឺមួលស៊ីកត្រចៀកអ្នកទាំងអស់គ្នា ដែលគេពុំឃើញ ៗ មុនទើបទៅដេញចាប់ញៀចគេនោះ អ្នកបានខ្នាច់នោះគេស្រែកជាសញ្ញាថា "ញៀច" ។ ពេលនោះ បើអ្នកណាមុជទឹកទាន់ អ្នកនោះត្រូវរួចខ្លួន អ្នកដេញញៀចមិនត្រូវញៀចគេទេ ។

១— អ្នកស្រាកខ្លះទេះលេងក្រោកពីរណ្ដើរយកក្ដុះ ពេលនោះតែម្ដង មិនចាប់ឈប់ចាំគ្នងទេ ។

www.elibraryofcambodia.org

ល្បែងនេះ ជាល្បែងមួយ សម្រាប់លេងជាកំសាន្តផង សម្រាប់ហាត់ភ្នែកឲ្យរហ័សឲ្យវៃ ក្នុងការពិនិត្យរកវត្ថុផ្សេងៗ និងជាកីឡាហែលទឹក គឺការហាត់ហែលទៀតផង ។

※

※ ※

www.elibraryofcambodia.org

# ២០- ល្បែងលាក់ឈ្នួង

ល្បែងលាក់ឈ្នួង ជាល្បែងសម្រាប់ក្មេងប្រុស ឬស្រីជំទង់ៗ តែប្រុសសុទ្ធតែប្រុស ស្រីសុទ្ធតែស្រី លេងកំសាន្តនៅពេលទំនេរ, គេលេងតែពេលថ្ងៃ នៅក្រោមម្លប់ឈើ ឬទីវាលពេលមេឃត្រជាក់ក៏បាន ។

សមាសភាពនៃអ្នកលេង មានគ្នាយ៉ាងតិចត្រឹម ៤ នាក់ឡើងទៅ ។

សកម្មភាពនៃអ្នកលេង ដូចក្នុងរូបភាពនេះ :



• មុននឹងលេង គេបបួលគ្នា ២ នាក់ អង្គុយសណ្ដូកជើងទាំង ២ ជាជួរទន្ទឹមគ្នា ផ្កាប់បាតដៃទាំង ២ ឬក្ដោបដាក់លើក្បាលជង្គង់ទាំង ២ ។

www.elibraryofcambodia.org

មានក្មេង ៤ នាក់ទៀតមិនអង្គុយសណ្តូកជើងទេ គេឲ្យម្នាក់កាន់ធ្យូងវែង ១ ដុំតូចល្មម ឬដុំក្រួសក៏បាន ដើរចាប់បើកបាតដៃរបស់អ្នកដែលអង្គុយក្តោបដៃដាក់លើក្បាលជង្គង់នោះ ម្តង ១ ៗ ធ្វើជាបម្រុងនឹងដាក់ធ្យូងទៅបាតដៃអ្នកទាំងនោះ រួចដាក់ធ្យូងនោះទៅក្នុងដៃក្តោបអ្នកណាមួយយ៉ាងរហ័សហើយឲ្យម្នាក់ទៀតចាំទាយ ។ កាលគេដាក់ធ្យូងរួចហើយអ្នកទាយ ក៏ចាប់ទាយឡើងថា "ធ្យូងនៅលើអ្នកនេះ" (ថាចំឈ្មោះអ្នកអង្គុយណាមួយ ដែលខ្លួនយល់ថាគេលាក់ធ្យូងនៅដៃរបស់គេ) ។

បើទាយត្រូវ អ្នកដែលទាយត្រូវនោះមានអំណាចកាន់ដុំធ្យូងលាក់វិញម្តង ។ ឯក្មេងដែលត្រូវគេលាក់ធ្យូងក្នុងដៃរួចហើយនោះ ក្រោកទៅចាំទាយធ្យូងវិញ ។ ក្មេងដែលកាន់ធ្យូងលាក់ពីគ្រាមុននោះ មកអង្គុយសណ្តូកជើងត្រង់កន្លែងដែលក្មេងក្រោកនោះវិញ ។ តែបើទាយមិនត្រូវ អ្នកដែលលាក់ធ្យូងនោះកាន់ធ្យូងលាក់តទៅទៀត ។ គេលេងតែរបៀបនេះរហូតដល់ពេលឈប់លេង ។

ល្បែងលាក់ធ្យូងនេះ ជាល្បែងមួយ សម្រាប់លេងកំសាន្តផង សម្រាប់ហាត់មើលអាការទឹកមុខរបស់មនុស្សផង ព្រោះធម្មតាអ្នក

www.elibraryofcambodia.org

លាក់ល្បែងក្នុងដៃរបស់ខ្លួន តែងតែមានទឹកមុខប្លែកជាងគេ ល្មមឲ្យអ្នកចាំទាយសង្កេតបាន ទាយត្រូវ, ជាល្បែងយោលទៅខាងផ្លូវតុលាការ ឬភ្នាក់ងារអ្នកស៊ើបអង្កេតផ្សេង ៗ ដើម្បីឲ្យងាយស៊ើបអង្កេតដោយគ្រាន់តែពិនិត្យទឹកមុខមនុស្ស ក៏អាចទាយថា ជាមនុស្សសុចរិត ឬទុច្ចរិតបាន ។

※

※ ※

www.elibraryofcambodia.org

# ២១- ល្បែងប៉ាក់ចាប

ល្បែងប៉ាក់ចាប ជាល្បែងខ្មែរមួយយ៉ាង លេងដោយកុមារកុមារីធំៗ ឬកម្លោះក្រមុំក៏អាចលេងបាន, តែគេច្រើនលេងដោយពួកៗ គឺប្រុសសុទ្ធតែប្រុស ស្រីសុទ្ធតែស្រី ហើយគេលេងនៅពេលណាក៏បាន តែច្រើនតែពួកក្មេងៗ គង្វាលគោ-ក្របី ដែលដេញហ្វូងគោក្របីរបស់ខ្លួនទៅឲ្យស៊ីស្មៅនៅវាលស្រែ ពេលព្រឹក ឬល្ងាច ហើយលេងកំសាន្តសប្បាយនៅក្រោមម្លប់ឈើ ក្នុងពេលដែលក្របី-គោរបស់ខ្លួនកំពុងស៊ីស្មៅយ៉ាងស្ងៀមស្ងាត់ ។

របៀបលេង ដំបូងគេបបួលគ្នាឲ្យបានចាប់ពី ២ នាក់ឡើងទៅ, គេរកគ្រាប់គ្រួសឲ្យបាន ៥ ឬ ១០ គ្រាប់ក្នុងម្នាក់ៗ តែចំនួនគ្រាប់នេះ មិនកំណត់ជា ៥ ឬ ១០ នោះទេ ស្រេចតែអ្នកលេងទាំងសងខាងព្រមព្រៀងកំណត់គ្នាជាមុន ។ តែតាមធម្មតា គេច្រើនតែកំណត់ត្រឹម ៥ គ្រាប់ម្នាក់ប៉ុណ្ណោះ ។ ល្បែងនេះគេលេងដោយចាត់ជាថ្នាក់ៗ គឺ លាក់, ពាយ, ប៉ក់, គេឈ្នះចាញ់ ។

www.elibraryofcambodia.org

ក្នុងទីនេះ និយាយចំពោះតែអ្នកលេង ២ នាក់ និងគ្រាប់សម្រាប់លេង ៥ គ្រាប់ម្នាក់ ដើម្បីងាយយល់តាមលំដាប់ថ្នាក់ដូចតទៅ :

សកម្មភាពនៃអ្នកលេង ដូចរូបភាពនេះ :



ថ្នាក់ទី ១- លាក់ កាលគេរកគ្នាជាអ្នកលេង និងគ្រាប់សម្រាប់លេងបានហើយ គេអង្គុយទល់មុខគ្នា ដៃម្ខាងក្ដាប់គ្រាប់គ្រួស ដៃម្ខាងទុកឲ្យនៅទំនេរគ្រប់គ្នា ។ គេលាក់គ្រាប់គ្រួសនោះ ដោយដាក់ដៃទាំង ២ មកខាងក្រោយខ្លួនទាំងអស់គ្នា ហើយបន្ទុចគ្រាប់គ្រួសមកដាក់ខាងដៃទទេ (ដាក់ប៉ុន្មានក៏ស្រេចតែចិត្តរបស់ខ្លួនគ្រប់គ្នា) ដោយប្រុងប្រយ័ត្នកុំឲ្យអ្នកលេងទាំងអស់គ្នាដឹង, ចំណែកដៃដែលដាក់គ្រាប់ថ្មនេះ ក៏គេក្ដាប់ឲ្យជិតមកដាក់ពីមុខរៀងខ្លួន ។

ថ្នាក់ទី ២- ទាយ កាលលាក់រួចស្រេចគ្រប់គ្នាអស់ហើយ គេក៏ចាប់ទាយ, ឧបមាថា អ្នកទី ១ ទាយថា ៣, អ្នកទី ២ ទាយថា ៤

www.elibraryofcambodia.org

រួចហើយគេបើកដៃក្តាប់នោះទាំងអស់គ្នាឡើង, រាប់គ្រាប់មើលទាំងអស់គ្នា ឃើញអ្នកទី ១ ដាក់ ១ គ្រាប់ អ្នកទី ២ ដាក់ ៣ គ្រាប់ រួមចំនួនគ្រាប់ដែលលាក់ទាំង ២ នាក់ ត្រូវជា ៤ គ្រាប់, ដូច្នេះ ការទាយទាំង ២ នាក់នេះឈ្មោះថាខុសទាំងអស់គ្នា, ត្រូវចាប់ផ្តើមលាក់សាជាថ្មីម្តងទៀត ហើយទាយដូចមុន ៗ ប្រសិនបើអ្នកទី ១ ទាយថា ៥ អ្នកទី ២ ទាយថា ៣ លុះបើកដៃឡើងឃើញអ្នកទី ១ ដាក់ ២ អ្នកទី ២ ដាក់ ៣ រួមគ្រាប់ទាំង ២ នាក់ត្រូវជា ៥ ដូច្នេះ ការនេះឈ្មោះថាអ្នកទី ១ ទាយត្រូវ អ្នកទី ១ ត្រូវប្រមូលគ្រាប់ទាំងអស់ពីអ្នកទី ២ មកដាក់បញ្ចូលគ្នាជាមួយនឹងគ្រាប់របស់ខ្លួនទាំងអស ៗ

ហ្នឹទី ៣- ប៉ក់ អ្នកប៉ក់ទី ១ ដាក់គ្រាប់ទាំងអស់ក្នុងកំបង់ដៃម្ខាង ហើយលើកគ្រាប់ទាំងអស់នោះបោះទៅលើបន្តិច ដោយដៃម្ខាង[១]ជួម ៗ កុំឲ្យគ្រាប់បាចសាចពាយប៉ាយរួចត្រឡប់ត្រងគ្រាប់ទាំងអស់នេះ ដោយខ្នងដៃ ទុបមាថាត្រងបាន ៤ គ្រាប់ ហើយលើកគ្រាប់ ៤ នោះបោះទៅលើម្តងទៀត រួចត្រឡប់ត្រងចាប់ខាងបាតដៃវិញ បើចាប់បានមិនជ្រុះឈ្មោះថាបាន ៤ គ្រាប់នោះ . បើត្រឡប់ចាប់ខាងបាតដៃនោះ មានជ្រុះ

---

១– បើគេរាប់សព្វាគ្នាថាលេងប៉ក់ដៃ ២ ទើបគេប៉ក់តែពីរ បើសព្វាគ្នាថាប៉ក់ដៃ ១ ក៏ប៉ក់តែ ១ ទៅ ៗ

ខ្វះគេហៅថា "ក្អួត" អ្នកបក់ទី ១ នោះត្រូវស្អុយ មិនត្រូវបានគ្រាប់អ្វីបន្តិចបន្តួចទេ ត្រូវប្រគល់គ្រាប់ទាំងអស់ទៅអ្នកទី ២ ឲ្យគេបក់ម្ដងវិញ ។ អ្នកទី ២ ក៏ត្រូវចាប់ផ្ដើមបក់ដូចអ្នកទី ១ ដែរ, ឧបមាថា បើអ្នកទី ២ នេះបក់ទៅគ្មានក្អួតបាន ៣គ្រាប់នោះ គ្រាប់ត្រូវនៅសល់តែ ៧ ទេ, អ្នកទី១ក៏ប្រមូលគ្រាប់ទាំង ៧ នេះទៅបក់ទៀត ឧបមាថា បាន ៤ គ្រាប់, ដូច្នេះគ្រាប់ត្រូវសល់តែ ៣, អ្នកទី ២ យកគ្រាប់ទាំង ៣ នេះទៅបក់ ឧបមាថាអ្នកទីពីរបក់បានទាំង ៣ គ្រាប់នេះតែម្ដង ដូច្នេះឃើញថាអស់គ្រាប់ហើយ ។

**ប្រាក់ទី ៤.– រកឈ្មោះបាញ់ .—** អម្បាញ់មិញនេះអ្នកលេងទាំងពីរនាក់ គឺអ្នកទី ១ បក់បានតែ ៤ គ្រាប់ ឯអ្នកទីពីរបក់បានដលទៅ ៦ គ្រាប់; ដូច្នេះអ្នកទី ១ ត្រូវខ្វះ ១គ្រាប់, អ្នកទីពីរ លើស ១ គ្រាប់ ហើយអ្នកទី ១ ត្រូវខ្ចីពីអ្នកទីពីរមួយគ្រាប់ ដើម្បីឲ្យបានគ្រប់ជា ៥ គ្រាប់ ដូចដែលបានកំណត់ពីខាងដើម ហើយចាប់ផ្ដើមបក់សាជាថ្មីឡើងទៀត ។

ការលេងមួយលើកមកនេះ ឃើញថាអ្នកទី ១ ជំពាក់អ្នកទី ២ មួយគ្រាប់ហើយ, បើលេង ១លើកទៀត អ្នកទី ១ ជំពាក់គេ ២ ឬ ៣គ្រាប់ទៀត សងគេវិញពុំរួចទេ, លុះជំពាក់គេដល់ ១០ គ្រាប់ត្រូវឲ្យគេដោះម្ដង ព្រោះល្បែងនេះ គេកំណត់ត្រឹមជំពាក់ ១០ ត្រូវដោះម្ដង បានឈ្មោះថា ចាញ់ ១ទឹកដែរ ។ ប៉ុន្តែបើអ្នកទី ១នេះ បក់បានច្រើនគ្រាប់

www.elibraryofcambodia.org

លើសពីគ្រាប់ដែលកំណត់នោះ គេអាចសងទៅអ្នកចំ ២ វិញបាន ។ សងប៉ុន្មានគ្រាប់ឈ្មោះថាបានរួចប៉ុណ្ណោះដែរ ។

ការដែលដោះនោះ គឺគេខាតក្បាលជន្គង់ដោយក្រញាំដៃ, ដោះមាន ២បែបគឺដោះបាយក្តៅ ១ បែប, ដោះបាយត្រជាក់ ១ បែប ។ បើដោះបាយក្តៅ គេខាតខ្លាំងៗចំនួន ១០ ឬ ១៥ដង ។ បើដោះបាយត្រជាក់គេខាតតិចៗស្រាលៗ ចំនួន ១១ឬ១៥ដងដែរ ។ ដោះហើយគេចាប់លេងសាជាថ្មីទៀត, គេលេងតែរបៀបនេះរហូតដល់ពេលឈប់ ។

ល្បែងនេះ គេលេងដើម្បីជាការកំសាន្តផង ដើម្បីហាត់ហ្វឹកហ្វឺនចិត្តគំនិត· ឲ្យស្គាល់អធ្យាស្រ័យរបស់មនុស្សទូទៅក្នុងការលាក់ពុតឬគាថកំបាំងផ្សេងៗផង ។

※

※ ※

www.elibraryofcambodia.org

# ២២_ ល្បែងបគ្រង្គ(១)

## តាមនៃបគ្រង្គ

ល្បែងប្រភេទនេះ កើតមានមកតាំងអំពីបុរាណកាល ជាល្បែងសម្រាប់កងទ័ពលេង ឲ្យមានប្រាជ្ញាវាងវៃ ក្នុងការប្រើកលឧបាយក្នុងចម្បាំង ។ ល្បែងនេះ មានឈ្មោះហៅ ៣ យ៉ាង គឺ ល្បែងអុក, ល្បែងឈើគ្រង់, ល្បែងបគ្រង្គ ។

ល្បែងអុក បានជាហៅយ៉ាងនេះ ព្រោះល្បែងនេះ មានគោលដៅសម្លាប់ខុន ។ តាមធម្មតា បើកូនបគ្រង្គណាមួយ ដែលអ្នកលេងចាប់យកទៅទន្ទឹមយ៉ាងខ្ជាំង ដាក់ក្នុងក្រឡាដែលអាចស៊ីខុនបាន គេតែងបន្លឺពាក្យថា "អុក" ហេតុនោះ ល្បែងប្រភេទនេះ ទើបគេហៅថា "ល្បែងអុក" ។

ឈើគ្រង់ ៖ ពាក្យនេះ ស្ដាប់ទៅ ហាក់ដូចជាពាក្យផ្ដុំបទនឹង ឈើរៀប តែពិនិត្យគេន័យក្នុងពាក្យ ឈើគ្រង់ ដែលជាឈ្មោះល្បែងនេះ មិនឃើញមានសោះ ។ ព្រោះហេតុនោះ ពាក្យថា ឈើគ្រង់

---

១– លោក យូរ-អ៊ុន សមាជិកនៃក្រុមជំនុំព្រះត្រៃបិដក រៀបរៀង

www.elibraryofcambodia.org

ក្នុងទីនេះ ប្រាកដជាក្លាយមកអំពីពាក្យថា ចត្រង្គ ។

ចត្រង្គ : ពាក្យនេះ ក្លាយមកអំពីភាសាសំស្ក្រឹត និងបាលីថា ចតុរង្គ ប្រែថា "មានអង្គបួន" ។ ល្បែងនេះ មានវិធីលេងដូចជាចម្បាំង ដែលមានសេនាកងទ័ពប្រកបដោយអង្គ ៤ គឺ កងទ័ពដំរី, កងទ័ពសេះ, កងទ័ពរថ និង កងទ័ពថ្មើរជើង ព្រោះហេតុនោះ ល្បែងនេះ ទើបឈ្មោះថា ចត្រង្គ ។ ពាក្យថា "ចត្រង្គ" នេះ មិនមែនក្លាយមកអំពីពាក្យថា ចតុរង្ស ដែលប្រែថា "មានជ្រុងបួន" ទេ ព្រោះមានន័យផ្ទុយពីល្បែងនេះ(១) ។

## កូនចត្រង្គ

ប្រដាប់សម្រាប់លេងល្បែងនេះ គេហៅថា កូនចត្រង្គ ។ កូនចត្រង្គនោះ មានចំនួន ៣២ សម្រាប់លេងដើរលើក្តារបួនជ្រុង ដែលមានក្រឡា ៦៤ (ក្តារអុក) ។ បណ្តាកូនទាំង ៣២ នោះ មានកូន ២ ហៅថា ខុន ទុកជាស្តេចសោយរាជ្យ, មានកូន២ ហៅថា នាង ទុក

១ មានល្បែង ២ បែបទៀត ជាពួកចត្រង្គ ឬស្រដៀងគ្នានឹងចត្រង្គដែរ គឺ ស្គា និងរ៉ែក ។

— ស្គា ពាក្យនេះហៅកាត់ខ្ចីមកពី បាសកា ជាឈ្មោះល្បែងមួយប្រភេទពួកចត្រង្គដែរ តែមានមេតីរ ហៅថា តោ មានសណ្ឋានបួនជ្រុង មានរន្ធ ៦ សម្រាប់លើកទម្លាក់លើក្តារ, មានកូន២៤ ឬ ៣០ . . . ។

— រ៉ែក ឈ្មោះល្បែងមួយប្រភេទ ស្រដៀងនឹងចត្រង្គ ខុសគ្នាតែឈ្មោះកូន និង ការចាញ់ឈ្នះ មានបែបឲ្យស៊ីរ៉ែកទាំងសងខាង ឬបើអ្នកម្ខាងទាល់ប្រក ត្រូវអ្នកម្ខាងទៀតក្របសោបស៊ីបានទាំងអស់, ជាល្បែងសម្រាប់ពួកទាហានលេង ដូចចត្រង្គដែរ ។

www.elibraryofcambodia.org

ជាព្រះអគ្គមហេសី, មានកូន ៤ ហៅថា គោល ទុកជាសេនាបតី ឬមេទ័ព; មានកូន ៤ ហៅថា សេះ, មានកូន ៤ ហៅថា ទូក, មានកូន ១៦ ហៅថា ត្រី, កូនទាំងអស់នេះ ទុកជាសេនាយោធពល ។

## កំណើតនៃកូនបត្រង្គ

កូនបត្រង្គទាំង ៣២ នោះ គេធ្វើដោយភ្លុក, ស្នែង ឬឈើផ្សេងៗ មានឈើនាងនួន និងដើមដៃខ្លាជាដើម តាមដែលគេមានធនធាន និងមានពេលអាចធ្វើបាន ។ ដើម្បីកុំឲ្យអ្នកលេងច្រឡំកូនគ្នា, កូនបត្រង្គទាំង ៣២ នោះ គេធ្វើឲ្យមានពណ៌ជា ២ ពួក, ក្នុងមួយពួកៗ មាន ១៦ កូន គឺថា បើមួយពួក គេធ្វើដោយភ្លុក មួយពួកទៀត គេធ្វើដោយស្នែង, បើមួយពួក គេធ្វើដោយឈើនាងនួន មួយពួកទៀត គេធ្វើដោយឈើគ្រញូងជាដើម ។ ឯការធ្វើកូនបត្រង្គទាំងនោះ បើចង់ឲ្យបានល្អស្អាត ហើយឲ្យមានរូបរាងដូចៗគ្នា គេត្រូវធ្វើដោយគ្រឿងក្រឡឹង វៀរលែងតែសេះ ៤ ព្រោះសេះ គេក្រឡឹងពុំកើតទេ គេត្រូវឆ្លាក់ដោយគ្រឿងចម្លាក់ ។ ចំពោះអ្នកដែលគ្មានគ្រឿងក្រឡឹងវិញ គេឆ្លាក់កូនទាំងអស់នោះ ដោយកាំបិតបន្ទោះ ។

## រូបសណ្ឋាននៃកូនបត្រង្គ

បណ្ដាកូនទាំង ៣២ នោះ, ទូក ២ គេធ្វើឲ្យមានរូបសណ្ឋានដូច

www.elibraryofcambodia.org

សន្ទឹកសីមា ។ គោល ៤ គេធ្វើឲ្យមានរូបសណ្ឋាន ដូចសន្ទឹកសីមាដែរ តែមាឌតូចជាងខុន ។ នាង ២ គេធ្វើឲ្យមានរូបសណ្ឋាន ដូចតួចេតិយ តែមាឌតូចជាងគោល ។ សេះ ៤ គេធ្វើឲ្យមានរូបសណ្ឋានជាក្បាលសេះ ដែលមានមាត់, ច្រមុះ, ត្រចៀក, ក និងស្មា ។ ទូក ៤ គេធ្វើឲ្យមានរូបសណ្ឋាន ដូចថ្កូសសីមា ។ ត្រីតាំង ១៦ គេធ្វើឲ្យមានរូបសណ្ឋានមូលសំប៉ែត ប៉ុនប្រាក់ ១ កាក់ ហើយមានធ្វើសញ្ញាឲ្យដឹងថាពោះ ថាខ្នង ។ ឯក្ដារចត្រង្គ មានរូបសណ្ឋាន ៤ ជ្រុងស្មើ មិនកំណត់ទំហំទេ ហើយនៅខាងក្នុងផ្ទៃក្ដារនោះ មានក្រឡា ៦៤ ។

ឯរូបសណ្ឋាន នៃកូនចត្រង្គ និងក្ដារអុកទាំងនោះ ដូចមានរូបគំនូរខាងក្រោម ៖


ខុន


គោល


នាង


ក្ដារអុក


សេះ




ត្រី

www.elibraryofcambodia.org

# ដំណើរនៃកូនបត្រង្គ

កូនបត្រង្គទាំង ៣២ នោះ មានការដើរផ្សេងៗគ្នា តែមាន ដំណើរត្រូវគ្នា តាមឈ្មោះកូន គឺ

១- ទូក ដើរបណ្ដោយក្រឡា ដោយឥតព្រំដែន ដូចគំរូខាងក្រោមនេះ ៖




២- សេះ ដើរផ្លោះកាត់បញ្ឆៀង ៣ ក្រឡា ដូចគំរូខាងក្រោមនេះ ៖




www.elibraryofcambodia.org

៣– គោល ដើរបាន៥ផ្លូវ គឺដើរទៅក្នុងក្រឡាមុខខ្លួនមួយក្រឡា និង ក្រឡានៅជ្រុងទាំង ៤ ដែលជាប់នឹងក្រឡាខ្លួន ដូចគំរូខាងក្រោមនេះ ៖




៤– នាង ដើរបាន៤ផ្លូវ គឺដើរទៅក្នុងក្រឡា នៅជ្រុងទាំង ៤ ដែលជាប់នឹងក្រឡាខ្លួន ដូចគំរូខាងក្រោមនេះ ៖




៥ ខុន ដើរបាន៨ផ្លូវ គឺក្រឡាទាំង ៨ ដែលនៅជុំវិញខ្លួន ដូចគំរូខាងក្រោមនេះ ៖




www.elibraryofcambodia.org

៦– ត្រី ដែលមិនទាន់បក ដើររុលទៅក្នុងក្រឡាមុខខ្លួន មួយក្រឡាម្ដង ៗ ទាំងមានសិទ្ធិត្រូវស៊ីកូនបត្រង់ជាបដិបក្សទីនខ្លួន ដែលនៅក្នុងក្រឡាជ្រុង អមផ្លូវខ្លួនទាំងពីរជ្រុង ដូចមានគំរូខាងក្រោមនេះ ៖




បើត្រីនេះបកហើយ ត្រូវដើរបាន ៤ ផ្លូវ ដូចនាង ៗ ត្រីដែលឡើងទីជាត្រីបក (ដើរបកមកក្រោយបាន) នោះ ចំពោះតែត្រីណាដែលដើរដល់ក្រឡាជាព្រំដែន នៃកូនបត្រង់ជាបដិបក្ស គឺក្រឡាទាំង ៨ ដែលគម្រៀបត្រីទាំង ៨ មុនទីនលេង របស់បដិបក្ស ៗ ត្រីដែលដើរដល់ទីជាត្រីបកនោះ គេត្រូវដាក់ផ្ការពោះ ដើម្បីកុំឲ្យច្រឡំនឹងត្រីមិនទាន់បក ៗ

ដំណើរនៃកូនបត្រង់ ដូចបានពោលមកហើយនេះ គេសន្មតហៅថា "ដើរ" គឺដើរទូក, ដើរសេះ, ដើរគោល, ដើរនាង, ដើរខុន, ដើរត្រី ៗ

## ឥទ្ធិពលនៃកូនបត្រង់

កូនបត្រង់ទាំង ៣២ មានឥទ្ធិពលខ្លាំងទន់ខ្សោយខុសគ្នា តែស៊ីគ្នាដោយឈ្មោះកូន គឺទូក ៤ និងសេះ ៤ មានកម្លាំងខ្លាំងក្រៃលែង

www.elibraryofcambodia.org

ជាងកូនចត្រង្គទាំងអស់ ។ តែទូក គេកាចបន្ថយឥទ្ធិពលមកត្រឹមត្រីបក បាន ហៅថា "ទូកបក" សម្រាប់អ្នកលេងដើរឯក លេងប៉ះនឹងអ្នកលេងដើរអន់ ។ ទូកបកនេះ គេត្រូវរៀបដាក់ផ្សារ ក្នុងពួកក្រឡាសង្កាត់ទី ២ ត្រង់ក្រឡាណាក៏បាន ។ គោល ៤ មានកម្លាំងខ្លាំងដែរ តែមិនដល់កម្លាំងទូកនិងសេះទេ ។ នាងនិងត្រីបក មានកម្លាំងអន់ជាងគោលទាំង ៤ ។ ត្រីមិនទាន់បក មានកម្លាំងអន់ ជាងនាងនិងត្រីបក ។ ឯខុន នឹងថាមានឥទ្ធិពល ឬគ្មានឥទ្ធិពុំបានទេ ព្រោះខុនមានមុខនាទីតែរត់គេច កុំឲ្យគេសម្លាប់ខ្លួន ហើយដែលស៊ីគេបាន ចំពោះតែគ្មានគេស៊ីខ្លួនវិញ ។

## ផ្តើមចេញយុទ្ធ

កាលអ្នកលេងបានរៀបកូនចត្រង្គរួចស្រេចហើយ តទៅ ត្រូវចេញដំណើរកូនចត្រង្គ ។ បណ្ដាអ្នកលេងទាំង ២ បក្ស ត្រូវឲ្យបក្សណាមួយ ចេញដំណើរកូនចត្រង្គមុន ស្រេចហើយត្រឹមនិយាយគ្នា ។ តែកាលបើលេងលើកទី ១ មានចាញ់មានឈ្នះហើយ, ដល់មកលេងលើកទី ២ ត្រូវបក្សឈ្នះចេញដំណើរកូនចត្រង្គមុន ។ តាមទម្លាប់នៃអ្នកលេងចត្រង្គ, មុនដំបូងបង្អស់ ច្រើនដើរត្រីនៅមុខខុនឲ្យបានត្រី ២ ឬ ៣ សិន រួចហើយទើបចេញដំណើរកូនចត្រង្គដទៃ តាមដំណើរនៃកូន ដូចបានពោលហើយ លើកលែងតែដំណើរនាង និងខុនចេញ ។ ព្រោះនាង

www.elibraryofcambodia.org

និងខុន ធ្វើដំណើរមុខដំបូង មានសិទ្ធិដើរផ្លោះក្រឡាបាន គឺនាងដើរផ្លោះរំលង ១ ក្រឡា ដែលនៅមុខខ្លួន ទៅនៅក្នុងក្រឡាទី ៣ ត្រង់កន្លែងដែលរៀបត្រីជាដំបូង ។ ឯខុនដើរផ្លោះកាត់បំហៀង ៣ ក្រឡា ដែលនៅឆៀងខាងមុខខ្លួន ។ តែពីនោះមក នាងនិងខុននេះ ត្រូវដើរតាមរបៀបប្រក្រតីខ្លួនវិញ ។ ចូរមើលរបៀបចេញដំណើរមុនដំបូង ដូចគំរូខាងក្រោមនេះ ៖

បីខ្ទង់ខាងលើ កូនបត្រង្គនៃបក្សលើ




បីខ្ទង់ខាងក្រោម កូនបត្រង្គនៃបក្សក្រោម

## ពាក្យសម្រាប់ប្រើក្នុងល្បែងបត្រង្គ

ក្នុងល្បែងបត្រង្គ មានពាក្យថា ស៊ី, ចង, ជាយ, អង់,

www.elibraryofcambodia.org

អុក, បិទ, អុកបែក, អាប់ ជាពាក្យនិយាយប្រាប់គ្នាឡើងជើង តាមហេតុការណ៍ដែលមាន ។

ស៊ី : ពាក្យនេះ ប្រើនិយាយចំពោះកូនចត្រង្គណា នៅក្នុងក្រឡាដែលជាជើងរបស់គេ គេអាចស៊ីកូនចត្រង្គនោះបាន ដូចទូកនៅក្នុងជើងសេះ, សេះអាចស៊ីទូកនោះ; ចូរមើលគំរូខាងក្រោមនេះ ៖

| | | |
|---|---|---|
| | | ទូក |
| សេះ | | |
| | | |

ទូកនៅក្នុងជើងសេះ ។

ទូកនិងសេះជាបក្សផ្សេងគ្នា ។

ចង : កូនចត្រង្គណា នៅក្នុងក្រឡាដែលជាជើងនៃកូនចត្រង្គគេ ដែលគេអាចស៊ីបាន, នោះគេត្រូវរកកូនចត្រង្គដទៃ ដែលមានជើងអាចស៊ីទៅគេវិញ ឡើងដើរមកក្នុងក្រឡាផ្សេង គឺបើគេស៊ីមក យើងមានកូនស៊ីទៅគេវិញ ហៅថា "ចង" ដូចមានគំរូខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| | | ទូក | |
| សេះ | | | នាង |
| | | | |

ទូកនៅក្នុងជើងសេះ ។

ទូកនិងនាងជាបក្សមួយ ។

www.elibraryofcambodia.org

ដាយ : ពាក្យនេះ ប្រើនិយាយចំពោះខុននៅក្នុងជើងទូក ដែលមានកូនចត្រង្គណាមួយ ជាបក្សខាងទូកនៅស្ទះពាំង; កាលបើគេដើរកូនដែលស្ទះពាំងជើងទូកនោះ គេពោលថា "ដាយ" ព្រោះទូកនោះ គាប់ស៊ីខុនបាន, ខុននោះត្រូវរត់ បើរត់មិនរួច ឈ្មោះថាចាញ់គេ ដូចមានគំរូខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| | | | |
| ទូក | | ត្រី | ខុន |
| | | | |

ទូកនិងត្រីជាបក្សមួយ ។

ត្រីស្ទះពាំងជើងទូក ។

អង់ : ពាក្យនេះ ប្រើនិយាយចំពោះទូក ដែលដើរទៅនៅក្នុងក្រឡាដែលមានសិទ្ធិស៊ីខុន តែស៊ីមិនទាន់បាន ព្រោះខុននោះមានទ័ពខ្លួននៅស្ទះពាំងឲ្យទូក ហៅថា "អង់" ដូចមានគំរូខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| | | | |
| ទូក | | ត្រី | ខុន |
| | | | |

ត្រីនិងខុនជាបក្សមួយ ។

ត្រីស្ទះពាំងជើងទូក ។

www.elibraryofcambodia.org

អុក : ពាក្យនេះ ប្រើនិយាយចំពោះកូនចត្រង្គណា ដែលដើរទៅក្នុងក្រឡាមានជើងខ្ទួនត្រូវស៊ីខុន ដោយគេទង្គិចកូននោះយ៉ាងខ្លាំង ហើយពោលថា "អុក" ។ តែខុននិងខុន មិនអាចអុកគ្នាបានទេ ព្រោះខុនទាំង ២ ត្រូវដើរចៀសកុំឲ្យប៉ះជើងគ្នាទៅវិញទៅមកជាដរាប ដូចមានគំរូខាងក្រោមនេះ ៖




ទូកនិងខុនជាបក្សផ្សេងគ្នា ។

ទូកមានជើងត្រូវស៊ីខុន ។

បិទ : ពាក្យនេះ ប្រើនិយាយចំពោះការយកកូនណាមួយ ទៅដាក់បិទផ្លូវជើងទូក ដែលគេអុកខុនហើយ ដើម្បីការពារកុំឲ្យគេស៊ីខុននោះ. ដូចមានគំរូខាងក្រោមនេះ ៖




នាងនិងខុនជាបក្សមួយ ។

នាងត្រូវដើរមកបិទជើងទូក ។

www.elibraryofcambodia.org

អុកមែក   កូនចត្រង្គណាមួយដែលអុកខុនហើយ ហើយអាចស៊ីកូនដទៃបានផង ហៅថា "អុកមែក" ។ ឧទាហរណ៍ ដូចគេយកសេះអុកខុន, សេះនោះអាចស៊ីទូកបាន នៅវេលាដែលបក្សម្ខាងដើរខុនចេញហើយ ដូចមានគំរូខាងក្រោមនេះ :-




ខុននិងទូកជាបក្សមួយ
ដែលនៅក្នុងជើងសេះគេ ។

អាប់ : ពាក្យនេះសម្រាប់ប្រើហៅខុន ដែលចំពោះគេតាមដេញ, កាលខុននោះត្រូវដើរ តែដើរមិនរួច ព្រោះក្រឡានៅជុំវិញខ្លួន សុទ្ធតែជាជើងរបស់គេ, ខុននោះ ត្រូវផ្តួលខ្លួនដេកក្នុងក្រឡាខ្លួន ហើយគេពោលថា "អាប់" ។ ខុនដែលអាប់នេះ មិនបានឈ្មោះថាចាញ់គេ ទាំងខាងគេ ក៏មិនឈ្មោះថាឈ្នះដែរ ដូចមានគំរូខាងក្រោមនេះ ៖




ទូកនិងគោលជាបក្សមួយ
ដែលមានជើងព័ទ្ធខុនជាប់ ។

www.elibraryofcambodia.org

# តស៊ូផ្សងព្រេង

កាលបើទ័ព គឺកូនចត្រង្គរបស់បក្សណាមួយ ដែលបក្សម្ខាងបានស៊ីអស់ហើយ នៅសល់តែខុនមួយ, ខុននោះ ត្រូវខុនដែលមានទ័ពគឺកូនចត្រង្គនៅសល់ច្រើន តាមដេញសម្លាប់ ទាល់តែលែងរួច ។ តែដែលជាមកនេះ បានចំពោះតែខុននោះ មានត្រីមិនទាន់បក, បើត្រីនោះបកហើយ ខុនទាំង ២ ត្រូវដើរផ្សងព្រេង ដោយវិធីរាប់ជើង; បើរាប់ទៅ ឃើញហួសព្រំដែន ដែលបានកំរិតទុកហើយ គេទុកជាស្មើគ្នា, ខុនទាំង ២ មិនឈ្នះមិនចាញ់ ។ តែបើខុនឯកឯងនោះ ស្លាប់មុននឹងដល់ព្រំដែននៃការរាប់ ដែលបានកំរិតទុក គេទុកជាចាញ់ ។

ឯវិធីរាប់ជើងនោះ មុននឹងរាប់ គេត្រូវបូករួមកូនចត្រង្គទាំង ២ បក្សបញ្ចូលគ្នាសិន គឺ បើកូនទាំងអស់មាន ៤ ត្រូវរាប់ពី ៥ ឡើងទៅ, បើកូនទាំងអស់ មាន ៥ ត្រូវរាប់ពី ៦ ឡើងទៅ ។ល។ តាមទម្លាប់ ត្រូវអ្នកលេងចត្រង្គ ដែលជាបក្សអន់ មានសល់តែខុនមួយ ដើរខុនហើយរាប់ទៀត ដល់គ្រាបៀកនៃអ្នកដទៃផង ។

## ព្រំដែននៃការដើររាប់ជើង

ការដើរហើយរាប់ជើងផងនោះ ពោលតាមទម្លាប់នៃអ្នកលេងចត្រង្គថា : ត្រូវរាប់ទៅតាមជើងនៃកូនចត្រង្គមួយ ៗ ដែលសល់នៅ ដូចមាន

www.elibraryofcambodia.org

កំណត់ទុកតទៅនេះ :-

បើខ្ទង់ដែលមានសល់ក្នុងចត្រង្គ គឺ

ទូក ១ កប់ ១៦ ហៅថា ដើមទូក,

សេះ ១ កប់ ៦៤ ហៅថា ដើមសេះ,

គោល ១ កប់ ៤៤ ហៅថា ដើមគោល,

ត្រីបក ឬនាង កប់ ៦៤ ហៅថា ដើមត្រី ។

បើទូក, សេះ, គោល, នៅសល់តាំងមួយគូ ៗ ត្រូវកប់កាត់ពាក់កណ្ដាលពេល គឺ

ទូក ២ កប់ ៨ វិញ,

សេះ ២ កប់ ៣២ វិញ,

គោល ២ កប់ ២២ វិញ ។

ឯត្រីបក បើមានច្រើន ក៏មិនបន្ថយចំនួនកប់ឡើយ ។

បើនៅសល់ក្នុងចត្រង្គលាយចម្រុះគ្នា ត្រូវកប់តាមក្នុងចត្រង្គណាដែលមានដើមតិចជាងក្នុងឯទៀត គឺ

បើសល់ទូក ១ និងសេះ ២ ឬ ១ កប់ ១៦ (យកដើមទូក),

បើសល់ទូក ១ និងគោល ២ ឬ ១ កប់ ១៦ " ,

បើសល់ទូក ១ និងនាង ឬត្រីបក កប់ ១៦ " ,

www.elibraryofcambodia.org

បើសល់សេះ ២ ឬ ១ និងគោល ២ កប់ ៦២ (យកដើមគោល),

បើសល់សេះ ១ និងគោល ១ កប់ ៤៤ "

បើសល់សេះ ២ និងគោល ១ កប់ ៣២ (យកដើមសេះ),

បើសល់សេះ ១ និងនាងឬត្រីបក កប់ ៦៤ (យកដើមណាក៏បាន),

បើសល់សេះ ២ និងនាងឬត្រីបក កប់ ៣២ (យកដើមសេះ) ។

នៅមានការដើរផ្សងព្រេង ដោយវិធីកប់មួយបែបទៀត ដូចនឹងពោលតទៅនេះ ៖

បណ្ដាបក្សទាំងពីរ, បក្សមួយ នៅមានសល់តែខុននិងកូនចត្រង្គណាមួយ តែមួយ, បក្សមួយទៀត មានសល់កូនចត្រង្គច្រើនជាង តាំងអំពីពីរបីឡើងទៅ ។ កាលបើមានសល់កូនបែបនេះ គេត្រូវកប់ ៦៤ ហើយចាប់កប់ពី ១ រៀងរហូតដល់ ៦៤ ។ បក្សអន់ (ដែលមានតែខុន ១ និងកូន ១) ត្រូវកប់ កប់ឡើងៗ ។ បើបក្សដែលមានច្រៀបជាងនោះមានត្រី ហើយត្រីនោះដើរដល់ក្រឡាបក, បក្សអន់ ត្រូវត្រឡប់កប់តាមអំណាចដើរនៃកូនចត្រង្គ ដូចដែលពោលខាងលើនោះវិញ ។

## ការប្រុងប្រយ័ត្នក្នុងពេលប្រយុទ្ធ

អ្នកលេងចត្រង្គ កាលបើចាប់ផ្ដើមលេង ត្រូវមានការប្រុងប្រយ័ត្ន ២ យ៉ាង គឺ ប្រយ័ត្នកុំឲ្យកូនចត្រង្គណាខាងគេ ដែលមានឥទ្ធិពលតិច

www.elibraryofcambodia.org

ស៊ីកូនបត្រង្គខ្លួន ដែលមានឥទ្ធិពលច្រើន ដូចត្រីខាងគេ ត្រូវស៊ីសេះ, ទូក, គោល ជារបស់ខ្លួន តាំងត្រូវប្រយ័ត្នកុំឲ្យគេស៊ីដោយឥតថ្លៃ ៗ មួយទៀត ត្រូវប្រយ័ត្នជាបំផុត កុំឲ្យកូនបត្រង្គខាងគេ ចោមសម្លាប់ខុនជារបស់ខ្លួន ៗ ព្រោះគោលដៅក្នុងល្បែងបត្រង្គ ចំពោះត្រង់សម្លាប់ខុន, បើគេសម្លាប់ខុនបានហើយ ចាត់ទុកជាចាញ់គេ អស់ផ្លូវតវ៉ា ៗ

## ទោសក្នុងការលេងបត្រង្គ

ល្បែងបត្រង្គ ធ្វើឲ្យអ្នកលេងខ្លះជក់ជាប់ចិត្ត រហូតដល់ភ្លេចបាយ ភ្លេចទឹក ភ្លេចប្រកបការងារដែលត្រូវធ្វើ, តាំងរយៈវេលាដែលលេងមក កន្លងទៅច្រើនម៉ោងហើយ ក៏អ្នកលេងខ្លះភ្លេចគិតដល់, លុះដល់ឈប់លេង ព្រោះហេតុតែប្រើកិរិយាបថ អង្គុយគិតដើរបត្រង្គយូរ ហួសពេលវេលា ព្រមទាំងខានបរិភោគបាយទឹក អ្នកលេងបត្រង្គខ្លះ ច្រើនទៅជាខ្យល់ចាប់ ដេកមិនលក់ ធ្ងន់ធ្ងរស្មារតី សោប់សល់ កាន់ការអ្វីមិនមុតមាំ ៗ

ហេតុអ្វីក៏ល្បែងនេះ ធ្វើឲ្យអ្នកលេងជក់ចិត្តខ្លាំងម្ល៉េះ? ព្រោះល្បែងនេះ អ្នកលេងត្រូវប្រើគំនិតគិតឲ្យឃើញច្រើនជាន់ ច្រើនផ្លូវ ត្រូវប្រើស្មារតីប្រុងប្រយ័ត្ន គ្មានបន្ធូរជាដរាប ត្រូវប្រើកលឧបាយគ្មានស្រាក, ក្នុងទីបំផុត ក៏ត្រូវចាញ់ ឬឈ្នះ ឬក៏ស្មើគ្នា ៗ បណ្ដាបក្សទាំងពីរ, បុគ្គលដែលចាញ់ គិតថា "បានជាចាញ់ ព្រោះអញគិតខុសត្រង់នេះ, ព្រោះ

www.elibraryofcambodia.org

ភ្លេចស្មារតីត្រង់នោះ, ព្រោះចាញ់កលគេត្រង់នេះ, ដូច្នេះ ដល់គ្រាទី ២ អញត្រូវប្រុងប្រយ័ត្នកុំឲ្យភ្លាត់សោះ ត្រូវយកជ័យឲ្យបានវិញ" ។ ចំណែកខាងបក្សឈ្នះ សប្បាយចិត្តខ្លាំង តាំងចិត្តថា "ដល់គ្រាទី ២ អញត្រូវប្រឹងយកជ័យឲ្យបានទៀត" ។ តែគួរឲ្យអនិច្ចា! ការតាំងចិត្តថានឹងយកជ័យឲ្យបាននៃបក្សទាំង ២ នោះ ឥតបានដូចបំណងរាល់លើក រាល់គ្រានោះឡើយ, ម្ល៉ោះហើយ អ្នកលេងទាំងពីរបក្ស ក៏ចេះតែមិនអស់ចិត្តរៀងខ្លួន បើទុកជាលេងទៅចាញ់គេ ក៏ចិត្តមិនព្រមចាញ់ បើទុកជាលេងទៅឈ្នះគេ ក៏មិនសុខចិត្តនឹងការឈ្នះមិនដំណំ ឬឈ្នះមិនច្រើន ។ ព្រោះអាស្រ័យហេតុនេះ ទើបអ្នកលេងល្បែងនេះ ជក់ចិត្តជាខ្លាំង ។

អ្នកលេងបត្រង្គ មាន ២ ពួក គឺពួកមួយ ចូលចិត្តលេងមិនភ្នាល់, មួយពួកទៀត ចូលចិត្តលេងមានដាក់តំណាង ។ អ្នកលេង ទាំង ២ ពួកនេះ បាននាមថាជាអ្នកប្រព្រឹត្តអបាយមុខ ត្រូវទទួលសេចក្តីវិនាសនៃសុខភាពក្នុងរាងកាយ, ខូចពេលវេលាដែលត្រូវប្រកបការងារ, បើលេងហើយមានភ្នាល់ផង ក៏ត្រូវជួបសេចក្តីវិនាស នៃធនធានទ្រព្យសម្បត្តិច្រើនលើសលុប ។

## គុណក្នុងការលេងបត្រង្គ

ប្រយោជន៍ក្នុងការលេងបត្រង្គ មានតិចតួចស្តួចស្តើងណាស់

www.elibraryofcambodia.org

តែថាមានពុំបាន ។ តែបើរកឲ្យជ្រៅឆ្ងាយទៅ គិតគន់ឃើញមានខ្លះ ថា: ល្បែងចត្រង្គនេះ គួរចាត់ទុកជាកីឡា ផ្នែកខាងមនោពលកម្ម គឺល្បែងបង្ហាត់ចិត្តឲ្យវៃ ធ្វើចិត្តឲ្យមានមានះប្រកាន់មាំ ព្រាំតស៊ូក្នុងកិច្ចការ ដែលជាមុខនាទីខ្លួនត្រូវធ្វើ ។ គុណប្រយោជន៍ដោយត្រង់ក្នុងល្បែងនេះ ចំពោះវីរបុរស យកតម្រាប់តាមកលឧបាយក្នុងល្បែងចត្រង្គ ទៅប្រើក្នុងនយោបាយដឹកនាំប្រទេសជាតិ ឬយកទៅប្រើក្នុងសឹកសង្គ្រាម ។ ព្រោះអ្នកធ្វើនយោបាយក្តី អ្នកធ្វើចម្បាំងក្តី ត្រូវជាអ្នកចេះធ្វើកលឧបាយច្រើនជាន់ ច្រើនផ្លូវ មានប្រាជ្ញាវាងវៃ មានកលល្បិចច្រើនស្រទាប់ ធ្វើឲ្យគូសត្រូវងងឹតមុខ វង្វេងស្មារតី ឲ្យភ្លាត់ស្នៀត ទើបយកជ័យបាន ប្រៀបដូចជាអ្នកលេងចត្រង្គ ដែលមានប្រាជ្ញាវាងវៃ អាចចេះប្រើកលឧបាយ យកជ័យពីគូប្រកួតនឹងខ្លួនបាន ដូច្នោះឯង ។

## បរិយោសានកថា

អត្ថបទស្តីពីល្បែងចត្រង្គនេះ ខ្ញុំបាននិយាយសព្វគ្រប់អស់ហើយ គួរចាត់ទុកថាជា តម្រាល្បែងចត្រង្គ បានពិត, ដែលនៅសល់ចន្លោះ តែត្រង់និយាយប្រាប់ផ្លូវ ប្រាប់ឧបាយ ឲ្យអ្នកអាន លេងចត្រង្គទៅហើយ ពូកែវាងវៃ ប៉ិនប្រសប់ ចេះប្រើកលឧបាយ ឲ្យឈ្នះគេកបរហូត ឲ្យទៅជាអ្នកចត្រង្គជើងឯក ។ បានជានៅសល់ត្រង់រឿងនេះ ព្រោះខ្ញុំក

www.elibraryofcambodia.org

ពាក្យសរសេរប្រាប់ពុំកើត ពុំដឹងជានិយាយដូចម្ដេច ៗ ព្រោះការពន់វៃប៉ុនប្រសប់ ការយល់ដឹងចត្រង្គច្រើនជាន់ច្រើនស្រទាប់នៃជនណា ពិតជាជននោះ ឧស្សាហ៍លេងចត្រង្គ ជួនលេងប៉ះនឹងអ្នកនេះ ជួនលេងប៉ះនឹងអ្នកនោះ, ការប៉ិនប្រសប់ក្នុងដឹងចត្រង្គនោះ ក៏កើតមានបន្តិច ៗ ជាលំដាប់ទៅ ៗ តែចំពោះមនុស្សខ្លះ បើទុកជាព្យាយាមលេងយ៉ាងណា ក៏មិនបានទៅជាអ្នកចត្រង្គដ៏ឯកដែរ, ការណ៍នេះព្រោះអ្វី ? ព្រោះអ្នកនោះឯង មានសតិប្បញ្ញាដែលជាប់ពីកំណើត (សជាតិកប្បញ្ញា) ទន់អន់ជាខ្លាំង ៗ

អ្នកប្រព្រឹត្តគិតតែល្បែងវែងវិនាស
អ្នកលះលាសចៀសចាកល្បែងវែងចំរើន
អ្នកព្យាយាមប្រកបការណាឲ្យកើន
វែងចំរើនដោយក្ដីសុខទុក្ខគ្មានហោង ៗ

www.elibraryofcambodia.org

# បញ្ជីសៀវភៅ

# ដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| កច្ចាយនូបត្ថម្ភកៈ ភាគទី ១ | ១ សៀវភៅថ្លៃ | ២២,០០ |
| — — ២ | — | ៤៦,០០ |
| កង្ខាវិតរណី ភាគទី ១ | — | ១២,០០ |
| — — ២ | — | ១០,០០ |
| — — ៣ | — | ១១,០០ |
| — — ៤ | — | ១២,០០ |
| កាលាមសូត្រ និងបរាភវសូត្រ | — | ២,០០ |
| កុម្ភជាតក | — | ៣,០០ |
| ក្បួនភាជីសព្ទ | — | ០,០០ |
| ក្រុងសុភមិត្រ ភាគទី ១ | — | ៥,០០ |
| — — ២ | — | ៤,០០ |
| — — ៣ | — | ៣,០០ |
| ខេមាខេមសរណគាថា | — | ០ ០០ |
| គតិលោក ភាគទី ១ ដល់ទី ១០ | — | ៤,០០ |
| គម្ពីរវិធីសារ | — | ១០,៥០ |
| គិរិមានន្ទសូត្រ ( ពាក្យកាព្យ ) | — | ៣,០០ |
| គិហិបដិបត្តិពិស្តារ | — | ១០,០០ |
| គិហិបដិបត្តិសង្ខេប | — | ០,០០ |
| គោលសមថកម្មដ្ឋាន | — | ៤,០០ |
| គំរូក្បាច់ចាក់ខ្មែរ | — | ០,០០ |
| ឃរាវាសធម៌ | — | ០,០០ |
| ចតុប្បារិសុទ្ធិសីល | — | ៧,០០ |

www.elibraryofcambodia.org

| | | |
|---|---|---|
| បំរៀនដំណើរនិយម ភាគទី ១ | ១ សៀវភៅថ្លៃ | ៧:០០ |
| បំរៀនសត្តិភាព (ភាសាបារាំង) | — | ២៨,០០ |
| ច្បាប់ល្បើកថ្មី | — | ៤,០០ |
| ច្បាប់ផ្សេង ៗ ភាគ ១ | — | ៤,០០ |
| — — ២ | — | ៤,០០ |
| — — ៣ | — | ៤,០០ |
| ច្បាប់រាជនីតិ | — | ១,០០ |
| ច្បាប់សុភាសិត | — | ៣,៥០ |
| ច្បាប់ស្រីព្រះរាជនិពន្ធព្រះអង្គឌួង | — | ១០,០០ |
| ជ័យវរ្ម័នទី ៧ (អក្សរខ្មែរ) | — | ៨,០០ |
| ជ័យវរ្ម័នទី ៧ (ភាសាបារាំង) | — | ១០,០០ |
| ញាណកថា | — | ២,០០ |
| ដើមកំណើតអង្គរ (អក្សរខ្មែរ) | — | ០,០០ |
| ដើមកំណើតអង្គរ (ភាសាបារាំង) | — | ២៣,០០ |
| ដំណាលពុទ្ធចេតិយ | — | ០,០០ |
| ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៥០ | — | ១៤៥,០០ |
| — ១៩៥១ | — | ១៤៥,០០ |
| — ១៩៥៤ | — | ២០០,០០ |
| — ១៩៥៥ | — | ២១០,០០ |
| — ១៩៥៧ | — | ២៣០,០០ |
| — ១៩៥៩ | — | ២៣០,០០ |
| — ១៩៦០ | — | ២៣០,០០ |
| — ១៩៦១ | — | ២៣០,០០ |
| — ១៩៦២ | — | ២៣០,០០ |
| — ១៩៦៣ | — | ២៣០,០០ |
| — ១៩៦៤ | — | ២៣០,០០ |

www.elibraryofcambodia.org

| | | | |
|---|---|---|---|
| ទសបារមីកថា | . . . . . . | ១ សៀវភៅថ្លៃ | ៦,០០ |
| ទសធម្មសូត្រ | . . . . . . | — | ០,០០ |
| ទានកថា | . . . . . . | — | ៦,០០ |
| ទឹកទន្លេសាប | . . . . . . | — | ០,០០ |
| ទំនៀមការផ្ទាល់ខ្លួន | . . . . . . | — | ៧.០០ |
| ទុំទាវ | . . . . . . | — | ១០,០០ |
| ធម្មប្រទីប | . . . . . . | — | ១០,០០ |
| ធម្មបទដ្ឋកថា ភាគទី ១ | . . . . . . | — | ២៤,០០ |
| — — ២ | . . . . . . | — | ១៨,០០ |
| — — ៣ | . . . . . . | — | ១៨,០០ |
| — — ៤ | . . . . . . | — | ១៦,០០ |
| — — ៥ | . . . . . . | — | ១៦,០០ |
| — ៦ | . . . . . . | — | ២០,០០ |
| — — ៧ | . . . . . . | — | ១៩,០០ |
| — — ៨ | . . . . . . | — | ១៩,០០ |
| នាគោបមាទិកថា | . . . . . | — | ១,៥០ |
| នានាជាតក | . . . . . | — | ១២,០០ |
| បករណវិសេសោ | . . . . . | — | ០,០០ |
| បក្ខគណនាវិធី និងបក្ខសម្រេច | . . . . . | — | ៣,០០ |
| បញ្ចអភិណ្ហប្បច្ចវេក្ខណៈ | . . . . | — | ៣,០០ |
| បញ្ញាសជាតកបាលី ភាគទី ១ | . . . . | — | ១៦,០០ |
| — — ២ | . . . . | — | ១២,០០ |
| — — ៣ | . . . . | — | ១២,០០ |
| — — ៤ | . . . . | — | ១២,០០ |

www.elibraryofcambodia.org

| | | | |
|---|---|---|---|
| បញ្ញាសជាតកបាលី ភាគទី៥ | . . . . | ១ សៀវភៅថ្លៃ | ១៧.០០ |
| —សម្រាយ— ១ | . . . . | — | ២៤.០០ |
| — — ២ | . . . . | — | ១៩,០០ |
| — — ៣ | . . . . | — | ១៥,០០ |
| — — ៤ | . . . . | — | ១៩,០០ |
| — — ៥ | . . . . | — | ២០,០០ |
| បទានុក្រមរាមកេរ្តិ៍ | . . . . . | — | ៤,០០ |
| បព្ជជ្ជាខន្ធកសង្ខេប | . . . . | — | ៨,៥០ |
| បាតិមោក្ខសង្ខេប | . . . . . | — | ៨,០០ |
| បាយាសិរាជញ្ញសូត្រ | . . . . . | — | ២,០០ |
| បិសាចស្នេហា | . . . . . | — | ០,០០ |
| បុណ្ណោវាទសូត្រ | . . . . . . | — | ១,០០ |
| បេសនីយបត្រ | . . . . . | ១ សន្លឹក | ១,៥០ |
| ប្រជុំរឿងព្រេងខ្មែរ ភាគទី ១ | . . . . | ១ សៀវភៅថ្លៃ | ២០,០០ |
| — — ២ | . . . . | — | ២២,០០ |
| — — ៣ | . . . . | — | ១៨,០០ |
| — — ៤ | . . . . | — | ១៦,០០ |
| — — ៥ | . . . . | — | ២៥,០០ |
| ប្រជុំកងធម៌ — ១ | . . . . | — | ៩,០០ |
| — — ២ | . . . | — | ៨,០០ |
| ប្រវត្តិព្រះមហាពោធិព្រឹក្ស | . . . | — | ២,០០ |
| ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ | . . . . | — | ២៣,០០ |
| ប្រស្នាវិនយបិដកសង្ខេប | . . . . | — | ២៩,០០ |

www.elibraryofcambodia.org

| | | |
|---|---|---|
| ពន្លឺអាស៊ីទ្វីប . . . . . . . | ១ សៀវភៅថ្លៃ | ២២'០០ |
| ពាក្យកាព្យប្រដៅជនប្រុសស្រី . . . . . | — | ៣.០០ |
| ពាក្យកាព្យថ្លែងរឿងពុទ្ធប្បវត្តិ . . . . . | — | ៣,០០ |
| ពិធីទាំងសមាស (អក្សរខ្មែរ) ភាគទី ១ . . . . | — | ១៥,០០ |
| — — ២ . . . . | — | ១៧,០០ |
| — — ៣ . . . . | — | ១៥,០០ |
| ពិធីទាំងសមាស (ភាសាបារាំង) . . . . | — | ៣០,០០ |
| ពិធីក្នុងគ្រួសារខ្មែរ (ភាសាបារាំង) . . . . | — | ៤០,០០ |
| ពុទ្ធមាមកវិធី . . . . . . . | — | ៨,០០ |
| ពុទ្ធប្បវត្តិតាមគំនូរបិទ (ភាសាបារាំង) . . . | — | ១០,០០ |
| ពុទ្ធោវាទានុសាសនី . . . . . . | — | ៤,០០ |
| ព្រហ្មបរិយេកថា . . . . . . . . | — | ១៥.០០ |
| ព្រះបាទអសោក . . . . . . . | — | ១៦.០០ |
| ព្រះបត្តមកេរ . . . . . . . . | — | ១,០០ |
| ព្រះត្រៃលក្ខណ៍ និងសំវេគកថា . . . . | — | ៤,០០ |
| ព្រះវិន័យសង្ឃកម្ម ភាគទី ១ . . . . . . | — | ១៧,០០ |
| — — ២ . . . . . . | — | ១៨,០០ |
| ភាណវារបាលី . . . . . . . | — | ៤០,០០ |
| ភិក្ខុបាតិមោក្ខបាលី . . . . . . | — | ៦,០០ |
| ភោគកុលកុមារ . . . . . . . | — | ២០,០០ |
| មគ្គទេសនគរ ភាគទី ១ . . . . . . | — | ៨.០០ |
| — — ២ . . . . . . | — | ២០,០០ |
| មនោបុព្វកថា . . . . . . | — | ៣,០០ |
| មរណានុស្សតិកម្មដ្ឋាន . . . . . . | — | ៤,០០ |
| មហាវេស្សន្តរជាតក . . . . . . | — | ៤៩,០០ |
| មហាបុរសលក្ខណៈ . . . . . . | — | ៣.០០ |

www.elibraryofcambodia.org

| | | |
|---|---|---|
| មាតាបិតុឧបដ្ឋានកថា | ១ សៀវភៅថ្លៃ | ៦,០០ |
| មាយើង | – | ១០,០០ |
| មិត្រល្អ | – | ៦,០០ |
| មង្គលត្ថទីបនី ភាគទី ១ | – | ៣០,០០ |
| – – ២ | – | ៣៥,០០ |
| – – ៣ | – | ៤៥,០០ |
| – – ៤ | – | ៣៥,០០ |
| មិលិន្ទបញ្ហា ភាគទី ១ | – | ២០,០០ |
| – ២ | – | ២០,០០ |
| មួយរយគាថា | – | ០,០០ |
| រតនប្បកា | | ៧,០០ |
| របាំខ្មែរ (ភាសាបារាំង) | – | ៧០,០០ |
| រាមកេរ្តិ៍ពីវគ្គ ១ ដល់ ១០ | – | ៤,០០ |
| – ពី៥ – ៨០ | – | ៤,០០ |
| រូបតេមិយជាតក | ១២ សន្លឹក | ៥,០០ |
| រូបមហាជនកជាតក | – | ៥,០០ |
| រូបសុវណ្ណសាមជាតក។ | – | ៥,០០ |
| រឿងមរណមាតា | ១ សៀវភៅថ្លៃ | ១៦,០០ |
| " កាកី | – | ៧,០០ |
| " សព្វសិទ្ធិ | – | ១២,០០ |
| " ហង្សយន្ត | – | ១០,០០ |
| " ពុទ្ធិសែន | – | ១០,០០ |
| " ស័ង្ខសិល្បជ័យ | – | ២៣,០០ |
| " សុបិនកុមារ | – | ៧,០០ |
| " ខ្យងស័ង្ខ | – | ១៦,០០ |
| " ស្រទបចេក | – | ២៥,០០ |

www.elibraryofcambodia.org

| | | |
|---|---|---|
| រឿងព្រះជិនវង្ស | ១ សៀវភៅថ្លៃ | ៣[illegible]០០ |
| " ព្រះសុធន | — | ១៧,០០ |
| " ទិព្វសង្វារ ភាគទី ១ | — | ៣០,០០ |
| " — ២ | — | ៣០,០០ |
| " — ៣ | — | ៣០,០០ |
| " — ៤ | — | ៣០,០០ |
| " — ៥ | — | ៣០,០០ |
| ល្បើកខ្ទុំគ្មានខ្លួនហៅប៊ិន | — | ៣,០០ |
| លោកនយបករណ៍ ភាគទី ១ | -- | ២២,០០ |
| — — ២ | — | ២៣,០០ |
| លក្ខន្តិៈកសាងវិត្ត | — | ៨,០០ |
| វិចនានុក្រមខ្មែរ ភាគទី ១ | — | ២៨០,០០ |
| — — ២ | — | ៣០០,០០ |
| វិសលសូត្រ | — | ៣,០០ |
| វិជ្ជាបរណកថា និងគិរិមានន្ទសូត្រ | — | ៦,០០ |
| វិជ្ជាប្រាំបីប្រការ | — | ២០,០០ |
| វិនយបឋមកប៉ិនបរិហារ | — | ៣,៥០ |
| វិសុទ្ធិមគ្គ៖ បាលី ភាគទី ១ | — | ៥១,០០ |
| — — — ២ | — | ៥០,០០ |
| — — — ៣ | — | ៥០,០០ |
| វិត្តោទ័យ | — | ០,០០ |
| វេយ្យាករណ៍សំស្ក្រឹត | - | |
| សត្តបរិត្ត ទ្វាទសបរិត្ត | — | ១៧,០ |
| សតិបដ្ឋានសូត្រ | — | |
| សប្បុរិសធម៌ (ពាក្យកាព្យ) | — | |

www.elibraryofcambodia.org

| | | | |
|---|---|---|---|
| សមន្តប្បាសាទិកា ភាគទី ១ | ១ | សៀវភៅថ្លៃ | ៣៥,១០ |
| — — ២ | | — | ៥០,០០ |
| — ៣ | | — | ៥៨,០០ |
| — — ៤ | | — | ៦០,០០ |
| សម្ពន្ធមាណ | | — | ៤០,០០ |
| សាមណេរវិន័យ | | — | ៨,០០ |
| សារទេសនា | | — | ២,០០ |
| សាសនសុភាសិត ភាគទី ១ | | — | ១២,៥០ |
| — — ២ | | — | ៧,៥០ |
| — — ៣ | | — | ៨,០០ |
| សិលាចារិកនគរវត្ត | | — | ១៥,០០ |
| សីមាវិនិច្ឆ័យ | | — | ៣,១០ |
| សីលនិទ្ទេស | | — | ១៦,០០ |
| សិង្គាលោវាទសូត្រ | | — | ៦,០០ |
| សុភាសិតប្បកាសិនី | | — | ៧,០០ |
| សុភាសិតច្បាប់ស្រី | | — | ៦,០០ |
| សុភូតិសូត្រ | | — | ៤,០០ |
| សុវណ្ណជាតក | | — | ១៥,០០ |
| សុភទោសកថា | | — | ២,០០ |
| សុរិយយាត្រាឡើងស័ក | | — | ៣,០០ |
| សៀវភៅឃានដំណិះខ្មែរ | | — | ០,០០ |
| សេកសោមបណ្ឌិត | | — | ៣,០០ |
| សេចក្តីរំលឹកដាស់តឿន | | — | ៣,០០ |
| សំដែងអំពីព្រះនិព្វាន | | — | ៩,០០ |
| សំវេគនិយធម៌ | | — | ២,០០ |
| អក្ខទោសកថា | | — | ៣,០០ |

www.elibraryofcambodia.org

| | | |
|---|---|---|
| ឯកសហស្សរាត្រី ភាគទី ១១ . . . . | ១ សៀវភៅថ្លៃ | ៤,០០ |
| — — ១២ . . . . | — | ៤,០០ |
| — ១៣ . . . . | — | ៥,០០ |
| — — ១៤ . . . . | — | ៧,០០ |
| — — ១៥ . . . . | — | ១០,០០ |
| — — ១៦ . . . . | — | ៦,៥០ |
| — — ១៧ . . . . | — | ៥,៥០ |
| — — ១៨ . . . . | — | ៥,០០ |
| — — ១៩ . . . . | — | ៧,០០ |
| — — ២០ ដល់ ២៤ . . . | — | ៨,០០ |
| — — ២៥ . . . . | — | ៦,០០ |
| — — ២៦ . . . . | — | ៧,០០ |
| — — ២៧ . . . . | — | ៧,០ |
| — — ២៨ . . . . | — | ៨,០០ |
| — — ២៩ . . . . | — | ៧,០០ |
| — — ៣០ . . . . | — | ៧,០០ |
| — — ៣១ ដល់ ៣៨ . . . | — | ៨,០០ |
| — — ៣៩ ដល់ ៤០ . . . | — | ៦,០០ |
| ភិក្ខុបាតិមោក្ខ . . . . . . . | — | ២០,០០ |
| អំពីប្រាសាទខ្លះនៅអង្គរ . . . . . . | — | ១៣,០០ |
| អំពីព្រះពុទ្ធសាសនា ( អក្សរខ្មែរ ) . . . | — | ៥០,០០ |
| អំពីព្រះពុទ្ធសាសនា ( ភាសាបារាំង ) . . . | — | ៥០,០០ |

www.elibraryofcambodia.org

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

រោងពុម្ព កាំបូជីយ៉ា ថ្លៃ ២៦៛០០

www.elibraryofcambodia.org